**អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី**

**របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016**

**អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី**

**របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016**

**មាតិកា** **ទំព័រ**


| | |
|---|---|
| របាយការណ៍ក្រុមប្រឹក្សាភិបាល | 1 - 3 |
| របាយការណ៍សវនករឯករាជ្យ | 4 - 7 |
| តារាងតុល្យការ | 8 |
| របាយការណ៍លទ្ធផល | 9 |
| របាយការណ៍បម្រែបម្រួលមូលធន | 10 |
| របាយការណ៍លំហូរសាច់ប្រាក់ | 11 |
| កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ | 12 - 55 |
| ឧបសម្ព័ន្ធ ៖ កំណត់សម្គាល់ស្តីពីការអនុវត្តតាមប្រកាសរបស់ធនាគារកណ្តាល* | i - viii |


*ឧបសម្ព័ន្ធមិនមែនជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មនេះទេ។

អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី
LOLC (Cambodia) Plc.

## របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលមានសេចក្តីសោមនស្ស ក្នុងការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច របស់ក្រុមហ៊ុន អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី (ហៅកាត់ថា "ក្រុមហ៊ុន") សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016។

## សកម្មភាពអាជីវកម្មចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាមីក្រូហិរញ្ញវត្ថុ (ទទួលប្រាក់បញ្ញើ និងផ្តល់កម្ចី) ដល់ប្រជាពលរដ្ឋនៅតាមជនបទ និងសហគ្រាសខ្នាតតូច តាមរយៈទីស្នាក់ការកណ្តាលរបស់ខ្លួននៅរាជធានីភ្នំពេញ និងសាខានៅតាមបណ្តាខេត្តមួយចំនួនទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ គោលដៅអាជីវកម្មរបស់ក្រុមហ៊ុន គឺផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលមានភាពជឿទុកចិត្ត និងដែលអាចទទួលយកបានដល់សហគ្រិនខ្នាតតូច។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុសម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016 ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផល នៅលើទំព័រទី ១។

## ឥណទានអាក្រក់ និងឥណទានសង្ស័យ

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ពាក់ព័ន្ធទៅនឹងការជម្រះឥណទានអាក្រក់ចេញពីបញ្ជី ឬការធ្វើសំវិធានធនឥណទានអាក្រក់និងសង្ស័យ ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថារាល់ឥណទានអាក្រក់ទាំងអស់ដែលបានដឹង ត្រូវបានជម្រះចេញពីបញ្ជី និងបានកត់ត្រាសំវិធានធនពេញលេញ សម្រាប់ឥណទានអាក្រក់ និងសង្ស័យ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលនាំឲ្យចំនួនសំវិធានធនឥណទានអាក្រក់និងសង្ស័យ ក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានតម្លៃមិនគ្រប់គ្រាន់ជាសារវន្តនោះទេ។

## ទ្រព្យសកម្ម

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មទាំងឡាយដែលទំនងជាមិនអាចបង្វិលមកវិញបាន នៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតាទៅតាមតម្លៃនៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ត្រូវបានកត់ត្រាបន្ថយឲ្យនៅស្មើនឹងតម្លៃដែលគិតថាអាចនឹងបង្វិលមកវិញបាន។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងអំពីហេតុការណ៍ណាមួយ ដែលអាចបណ្តាលឲ្យតម្លៃទ្រព្យសកម្មក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ពុំត្រឹមត្រូវជាសារវន្តនោះទេ។

## បំណុលយថាភាព និងបំណុលផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ មិនមាន ៖

(ក) បន្ទុកណាមួយលើទ្រព្យសកម្មរបស់ក្រុមហ៊ុន ដែលបានកើតឡើងដោយសារការដាក់វាបញ្ចាំ សម្រាប់ការធានាបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីដំណាច់ឆ្នាំមក ឬ

(ខ) បំណុលយថាភាពណាមួយរបស់ក្រុមហ៊ុន ដែលបានកើតឡើងចាប់តាំងពីដំណាច់ឆ្នាំមក ក្រៅពីបំណុលផ្សេងៗនៅក្នុងដំណើរការអាជីវកម្មធម្មតានោះទេ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាភាព ឬបំណុលផ្សេងៗរបស់ក្រុមហ៊ុនបានក្លាយជាការបង្ខំឱ្យសង ឬអាចនឹងត្រូវទាមទារឱ្យសងក្នុងអំឡុងពេល12ខែបន្ទាប់ពីដំណាច់ឆ្នាំ ដែលនឹង ឬអាចនឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅថ្ងៃដល់ពេលកំណត់សងនោះទេ។

## ការប្រែប្រួលកាលៈទេសៈ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលមិនបានដឹងពីកាលៈទេសៈណាមួយដែលមិនបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលអាចបណ្តាលឱ្យចំនួនទឹកប្រាក់ដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។

## ប្រតិបត្តិការមិនប្រក្រតី

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016 មិនបានទទួលរងនូវផលប៉ះពាល់ជាសារវន្តពីខ្ទង់គណនីប្រតិបត្តិការ ឬព្រឹត្តិការណ៍មិនប្រក្រតីណាមួយឡើយ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល នៅចន្លោះពេលរវាងដំណាច់ឆ្នាំនេះ រហូតមកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍ មិនមានខ្ទង់គណនីប្រតិបត្តិការ ឬព្រឹត្តិការណ៍ខុសប្រក្រតីណាមួយ ដែលអាចមានផលប៉ះពាល់ជាសារវន្តដល់លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្នុងឆ្នាំដែលរបាយការណ៍នេះត្រូវបានធ្វើឡើងនោះទេ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលនៅបម្រើការក្នុងអំឡុងឆ្នាំ រហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ មានរាយនាមដូចខាងក្រោម ៖

| | |
|---|---|
| លោក Brindley Chrishantha Gajanayake de Zylva | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក Ravindra Dhammika Tissera | អភិបាល |
| អ្នកស្រី Fernanda Pecanha Lacerda de Lima | អភិបាល |
| លោក Indrajith Wijesiriwardana | អភិបាល |
| លោក Hans Michael Theodor Moormann | អភិបាល |

LOLC

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល លើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង និងបានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2016 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ដំណាច់ឆ្នាំ។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលត្រូវ ៖

i) អនុវត្តគោលការណ៍គណនេយ្យសមស្រប ដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ប្រមាណសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តតាមគោលការណ៍ទាំងនេះឱ្យមានភាពស៊ីសង្វាក់គ្នា។

ii) អនុវត្តតាមតម្រូវការក្នុងការលាតត្រដាងព័ត៌មាន ដែលអនុលោមតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារកណ្តាល ហើយប្រសិនបើមានការប្រាសចាកណាមួយក្នុងការបង្ហាញឱ្យមានភាពពិត និងត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលប្រាកដថាការប្រាសចាកទាំងនោះត្រូវបានបង្ហាញ ពន្យល់ និងកំណត់ចំនួនទឹកប្រាក់បានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

iii) រក្សាទុកកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព។

iv) រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តភាពនៃដំណើរការអាជីវកម្ម លើកលែងតែមានករណីសន្មតសមរម្យថា ក្រុមហ៊ុននឹងមិនអាចបន្តកិច្ចប្រតិបត្តិការអាជីវកម្មនាពេលខាងមុខដ៏ខ្លី និង

v) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឲ្យមានប្រសិទ្ធភាព និងចូលរួមក្នុងការសម្រេចចិត្តសំខាន់ៗទាំងអស់ ដែលមានឥទ្ធិពលលើប្រតិបត្តិការ និងលទ្ធផលរបស់ក្រុមហ៊ុន ហើយធានាថាផលប៉ះពាល់ទាំងនោះត្រូវបានឆ្លុះបញ្ចាំងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថា ក្រុមហ៊ុនបានអនុវត្តតាមតម្រូវការខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## ការអនុម័តរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលធានាអះអាងថា របាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់មកជាមួយ បានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2016 និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារកណ្តាល។

ចុះហត្ថលេខាតាងនាមឲ្យក្រុមប្រឹក្សាភិបាល

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី
LOLC (CAMBODIA) Plc.
KINGDOM OF CAMBODIA

**លោក សុខ វឿន**
**នាយកប្រតិបត្តិ**

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទ៖ ថ្ងៃទី05 ខែមេសា ឆ្នាំ2017



គំនិតរីកចម្រើន

## របាយការណ៍សវនករឯករាជ្យ
## ជូនភាគទុនិក អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

### មតិយោបល់របស់យើងខ្ញុំ

តាមមតិយោបល់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុរបស់ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី (ហៅកាត់ថា "ក្រុមហ៊ុន") បង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់អំពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2016 និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់ សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិ នៃ កម្ពុជា (ហៅកាត់ថា "ធនាគារកណ្តាល")។

### របាយការណ៍ដែលយើងខ្ញុំបានធ្វើសវនកម្ម

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន រួមមាន៖

- តារាងតុល្យការគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2016
- របាយការណ៍លទ្ធផលសម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍បម្រែបម្រួលមូលធនសម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍លំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ និង
- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ រាប់ទាំងសេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ។

### មូលដ្ឋាននៃមតិយោបល់របស់យើងខ្ញុំ

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិ ស្តីពីសវនកម្មនៃកម្ពុជា (ហៅកាត់ថា "ស្តង់ដារសវនកម្ម")។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលអនុលោមទៅតាមស្តង់ដារទាំងនោះ ត្រូវបានពណ៌នាបន្ថែមទៀតនៅក្នុងកថាខណ្ឌ "ការទទួលខុសត្រូវរបស់សវនករក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ" នៅក្នុងរបាយ-ការណ៍សវនកម្មរបស់យើងខ្ញុំ។

យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំបានទទួល មានភាពគ្រប់គ្រាន់ និងសមហេតុផល ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

### ឯករាជ្យ

យើងខ្ញុំមានឯករាជ្យពីក្រុមហ៊ុន ដែលអនុលោមទៅតាមក្រមសីលធម៌សម្រាប់គណនេយ្យករវិជ្ជាជីវៈ ដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារក្រមសីលធម៌អន្តរជាតិ (ហៅកាត់ថា "ក្រមសីលធម៌អន្តរជាតិ") និងអនុលោមទៅតាមក្រមសីលធម៌របស់ វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (ហៅកាត់ថា "ក្រមសីលធម៌ វគសក")។ យើងខ្ញុំបានបំពេញកាតព្វកិច្ចក្នុងការទទួលខុសត្រូវផ្នែកក្រមសីលធម៌ផ្សេងៗទៀត ដែលកំណត់ដោយ "ក្រមសីលធម៌អន្តរជាតិ" និង "ក្រមសីលធម៌ វគសក"។

*PricewaterhouseCoopers (Cambodia) Ltd.*
*58C Sihanouk Boulevard, Sangkat Tonle Bassac, Khan Chamkarmon, Phnom Penh, Cambodia*
*T: +855 (0)23 860 606, F: +855(0)23 211 594, www.pwc.com/kh*

**ព័ត៌មានផ្សេងៗ**

គណៈគ្រប់គ្រងទទួលខុសត្រូវចំពោះព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗរួមមាន ឧបសម្ព័ន្ធស្តីពីការអនុវត្តតាមប្រកាសរបស់ធនាគារកណ្តាល ប៉ុន្តែឧបសម្ព័ន្ធទាំងនេះមិនមែនជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកររបស់យើងខ្ញុំទេ។

មតិយោបល់របស់យើងខ្ញុំចំពោះរបាយការណ៍ហិរញ្ញវត្ថុ ពុំបានគ្របដណ្តប់ទៅលើព័ត៌មានផ្សេងៗនោះទេ ហើយយើងខ្ញុំមិនធ្វើការធានាអះអាងចំពោះព័ត៌មានទាំងនោះទេ។

ទាក់ទងនឹងការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ យើងខ្ញុំទទួលខុសត្រូវក្នុងការអានព័ត៌មានផ្សេងៗដែលបានរៀបរាប់ខាងលើ ដើម្បីពិចារណាថាតើព័ត៌មានផ្សេងៗទាំងនោះមានភាពផ្ទុយគ្នាជាសារវន្តពីរបាយការណ៍ហិរញ្ញវត្ថុ ឬផ្ទុយពីការយល់ដឹងរបស់យើងខ្ញុំផ្អែកលើលទ្ធផលនៃការធ្វើសវនកម្ម ឬមានការរាយការណ៍ពីកំហុសឆ្គងជាសារវន្តដែលបានកើតឡើងឬទេ។

ផ្អែកទៅលើការងារដែលយើងខ្ញុំបានបំពេញ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តដែលកើតចេញពីព័ត៌មានផ្សេងៗទាំងនេះ យើងខ្ញុំត្រូវរាយការណ៍ពីអង្គហេតុនៃកំហុសឆ្គងទាំងនោះ។ យើងខ្ញុំមិនមានអ្វីត្រូវរាយការណ៍ចំពោះបញ្ហានេះទេ។

**ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងអ្នកដែលទទួលបន្ទុកអភិបាលកិច្ចរបាយការណ៍ហិរញ្ញវត្ថុ**

គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការរៀបចំ និងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុឲ្យបានត្រឹមត្រូវ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិ នៃ កម្ពុជា និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឲ្យចៀសផុតពីការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការវាយតម្លៃអំពីលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តភាពអាជីវកម្ម ការលាតត្រដាងព័ត៌មានដែលពាក់ព័ន្ធ ក៏ដូចជាបញ្ហាផ្សេងៗដែលទាក់ទិនទៅនឹងនិរន្តភាពអាជីវកម្ម ដោយប្រើមូលដ្ឋានគណនេយ្យសម្រាប់និរន្តភាពអាជីវកម្ម លើកលែងតែគណៈគ្រប់គ្រងគ្រោងនឹងបិទអាជីវកម្មរបស់ក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ដោយមិនមានជម្រើសណាផ្សេងប្រកបដោយភាពប្រាកដប្រជាណាមួយ។

អ្នកដែលទទួលបន្ទុកលើអភិបាលកិច្ច ត្រូវមានការទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការនៃការរាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

pwc

## ការទទួលខុសត្រូវរបស់សវនករ ក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំគឺស្វែងរកអំណះអំណាងដែលសមហេតុផល ថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលពុំមានការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ និងចេញរបាយការណ៍សវនកម្មដែលមានមតិយោបល់របស់យើងខ្ញុំ។ ការអះអាងដែលសមហេតុផលគឺជាការអះអាងក្នុងកម្រិតខ្ពស់ ប៉ុន្តែវាមិនមែនជាការធានាថាសវនកម្មដែលបានធ្វើឡើងដោយអនុលោមទៅតាមស្តង់ដារសវនកម្ម តែងតែរកឃើញជានិច្ចនូវការរាយការណ៍ខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការរាយការណ៍ខុសអាចកើតឡើងពីការក្លែងបន្លំ ឬកំហុសឆ្គង ហើយវាត្រូវបានចាត់ទុកថាមានលក្ខណៈជាសារវន្ត ប្រសិនបើការរាយការណ៍ខុសនីមួយៗ ឬការរាយការណ៍ខុសសរុប អាចត្រូវបានរំពឹងថាវាជះឥទ្ធិពលលើមូលដ្ឋាននៃការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

ផ្នែកមួយនៃការធ្វើសវនកម្មដែលអនុលោមទៅតាមស្តង់ដារសវនកម្ម តម្រូវឲ្យយើងខ្ញុំប្រើប្រាស់ការវិនិច្ឆ័យ និងរក្សាភាពងឿងឆ្ងល់ប្រកបដោយវិជ្ជាជីវៈក្នុងពេលបំពេញការងារសវនកម្មរបស់យើងខ្ញុំ ហើយយើងខ្ញុំ៖

- កំណត់ និងវាយតម្លៃហានិភ័យនៃភាពខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលអាចបណ្តាលមកពីការក្លែងបន្លំឬកំហុសឆ្គងផ្សេងៗ ដោយតាក់តែងនីតិវិធីសវនកម្ម និងធ្វើសវនកម្មដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងស្វែងរកភស្តុតាងសវនកម្មគ្រប់គ្រាន់និងសមស្រប ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលបណ្តាលមកពីការរកមិនឃើញកំហុសជាសារវន្តពីការក្លែងបន្លំ វាមានទំហំធំជាងហានិភ័យដែលបណ្តាលមកពីកំហុសឆ្គងអចេតនា។ ការក្លែងបន្លំរួមមាន ការសមគំនិត ការក្លែងបន្លំឯកសារ ការលុបបំបាត់ដោយចេតនា ការបង្ហាញខុស ឬការរំលងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធទៅនឹងសវនកម្ម ដើម្បីតាក់តែងនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនបញ្ចេញមតិយោបល់របស់យើងខ្ញុំទៅលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុនទេ។
- វាយតម្លៃអំពីភាពសមស្របនៃគោលការណ៍គណនេយ្យដែលបានប្រើប្រាស់ ភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការលាតត្រដាងពាក់ព័ន្ធ ដែលគណៈគ្រប់គ្រងបានធ្វើឡើង។
- សន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋានគណនេយ្យនិរន្តភាពអាជីវកម្ម របស់គណៈគ្រប់គ្រង អាស្រ័យទៅលើភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន ថាតើវាមានភាពមិនច្បាស់លាស់ជាសារវន្តដែលបានកើតឡើងកម្រិតណាពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌនានា អាចបណ្តាលឲ្យមានការសង្ស័យជាដុំកំភួន ទៅលើលទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបន្តនិរន្តភាពអាជីវកម្មរបស់ខ្លួនដែរឬទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា វាមានភាពមិនច្បាស់លាស់ជាសារវន្តបានកើតឡើង នោះយើងខ្ញុំត្រូវធ្វើការបង្ហាញនៅក្នុងរបាយការណ៍សវនកម្ម ដើម្បីទាញចំណាប់អារម្មណ៍អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ ចំពោះការលាតត្រដាងព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងនោះនៅមិនទាន់គ្រប់គ្រាន់ទៀត យើងខ្ញុំត្រូវធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។ សេចក្តីសន្និដ្ឋានសរុបរបស់យើងខ្ញុំ អាស្រ័យទៅលើភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន រហូតដល់ថ្ងៃចុះហត្ថលេខាលើរបាយការណ៍សវនកម្មនេះ។ ទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនានាក្នុងពេលអនាគត អាចបណ្តាលឲ្យក្រុមហ៊ុនឈប់បន្តនិរន្តភាពអាជីវកម្ម។

pwc

- វាយតម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងខ្លឹមសារក្នុងរបាយការណ៍ហិរញ្ញវត្ថុ រាប់ទាំងការលាតត្រដាងព័ត៌មានផ្សេងៗ និងកំណត់ថារបាយការណ៍ហិរញ្ញវត្ថុបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ជាក់ស្តែង ដែលអាចធ្វើឲ្យមានការបង្ហាញត្រឹមត្រូវ។

យើងខ្ញុំបានរាយការណ៍ជូនអ្នកដែលទទួលបន្ទុកអភិបាលកិច្ចនូវបញ្ហាផ្សេងៗដូចជា ទំហំការងារ និងពេលវេលាសវនកម្ម ព្រមទាំងបញ្ហាសវនកម្មសំខាន់ៗ រួមទាំងរាយការណ៍ពីភាពខ្វះខាតជាសារវន្តនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលយើងខ្ញុំបានរកឃើញក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំ។

**ជ. ក្រុមហ៊ុន** PricewaterhouseCoopers ( Cambodia ) Ltd.

**គុយ លីម**
Partner

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទ៖ ថ្ងៃទី05 ខែមេសា ឆ្នាំ2017

## តារាងតុល្យការ
### គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

| | កំណត់សម្គាល់ | 2016 ពាន់រៀល | 2016 ដុល្លារអាមេរិក | 2015 ពាន់រៀល | 2015 ដុល្លារអាមេរិក |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | 4 | 8,198,053 | 2,030,729 | 3,881,625 | 958,426 |
| សមតុល្យនៅធនាគារកណ្តាល | 5 | 13,289,293 | 3,291,873 | 34,040,692 | 8,405,109 |
| សមតុល្យនៅធនាគារផ្សេងៗ | 6 | 89,398,093 | 22,144,685 | 70,717,376 | 17,461,080 |
| ឥណទានអតិថិជន | 7 | 874,171,085 | 216,539,778 | 760,988,930 | 187,898,501 |
| ការវិនិយោគ | | 60,555 | 15,000 | 60,750 | 15,000 |
| ទ្រព្យសកម្មផ្សេងៗ | 8 | 20,564,216 | 5,093,935 | 23,366,207 | 5,769,434 |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | 9 | 9,285,666 | 2,300,140 | 6,335,578 | 1,564,340 |
| ទ្រព្យសកម្មអរូបី | 10 | 2,351,921 | 582,592 | 74,042 | 18,282 |
| ពន្ធពន្យារទ្រព្យសកម្ម | 11(ក) | 3,444,234 | 853,167 | 1,270,200 | 313,630 |
| **ទ្រព្យសកម្មសរុប** | | 1,020,763,116 | 252,851,899 | 900,735,400 | 222,403,802 |
| **បំណុល និងមូលធន** | | | | | |
| **បំណុល** | | | | | |
| ប្រាក់បញ្ញើរបស់គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | 12(ក) | 24,222,052 | 6,000,014 | - | - |
| ប្រាក់បញ្ញើអតិថិជន | 12(ខ) | 53,900,768 | 13,351,689 | 1,114,636 | 275,219 |
| ឥណទានវិបារូបន៍ | 13 | - | - | 3,980,411 | 982,818 |
| ប្រាក់កម្ចី | 14 | 708,288,413 | 175,449,198 | 717,145,414 | 177,072,942 |
| បំណុលផ្សេងៗ | 15 | 24,490,968 | 6,066,625 | 21,385,635 | 5,280,403 |
| បំណុលពន្ធលើប្រាក់ចំណេញ | 11(ខ-i) | 13,946,327 | 3,454,626 | 11,308,037 | 2,792,108 |
| **បំណុលសរុប** | | 824,848,528 | 204,322,152 | 754,934,133 | 186,403,490 |
| **មូលធន** | | | | | |
| ដើមទុន | 16 | 23,368,200 | 5,788,506 | 23,368,200 | 5,769,926 |
| ទុនបម្រុង | | 4,861,722 | 1,204,291 | 4,279,558 | 1,056,681 |
| ចំណេញរក្សាទុក | | 167,684,666 | 41,536,950 | 118,153,509 | 29,173,705 |
| **មូលធនសរុប** | | 195,914,588 | 48,529,747 | 145,801,267 | 36,000,312 |
| **បំណុល និងមូលធនសរុប** | | 1,020,763,116 | 252,851,899 | 900,735,400 | 222,403,802 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី 12 ដល់ទំព័រទី 55 គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

## របាយការណ៍លទ្ធផល
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

| | កំណត់សម្គាល់ | 2016 ពាន់រៀល | 2016 ដុល្លារអាមេរិក | 2015 ពាន់រៀល | 2015 ដុល្លារអាមេរិក |
|---|---|---|---|---|---|
| ចំណូលការប្រាក់ | 17 | 225,733,566 | 55,916,167 | 168,416,754 | 41,584,384 |
| ចំណាយការប្រាក់ | 18 | (71,261,995) | (17,652,216) | (49,092,922) | (12,121,709) |
| **ចំណូលការប្រាក់សុទ្ធ** | | 154,471,571 | 38,263,951 | 119,323,832 | 29,462,675 |
| ចំណូលផ្សេងៗ | 19 | 9,945,178 | 2,463,507 | 5,443,633 | 1,344,107 |
| ចំណាយកម្រៃជើងសារ | 20 | (1,347,679) | (333,832) | (2,753,366) | (679,843) |
| ចំណាយបុគ្គលិក | 21 | (48,559,704) | (12,028,661) | (37,369,599) | (9,227,061) |
| ចំណាយរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ | 9 | (3,584,159) | (887,827) | (2,223,346) | (548,974) |
| ចំណាយរំលស់ទ្រព្យសកម្មអរូបី | 10 | (20,699) | (5,128) | (19,309) | (4,770) |
| ចំណាយទូទៅ និងចំណាយរដ្ឋបាល | 22 | (27,458,553) | (6,801,722) | (18,843,924) | (4,652,821) |
| ចំណេញ/(ខាត)សុទ្ធពីការប្តូររូបិយប័ណ្ណ | | 474,778 | 117,607 | (460,539) | (113,713) |
| **ចំណេញប្រតិបត្តិការ** | | 83,920,733 | 20,787,895 | 63,097,382 | 15,579,600 |
| សំវិធានធនឥណទានអាក្រក់និងសង្ស័យ | 7 | (14,989,712) | (3,713,082) | (1,952,391) | (482,072) |
| **ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ** | | 68,931,021 | 17,074,813 | 61,144,991 | 15,097,528 |
| ចំណាយពន្ធលើប្រាក់ចំណេញ | 11 | (13,936,083) | (3,452,089) | (12,335,420) | (3,045,782) |
| **ចំណេញក្នុងឆ្នាំ** | | 54,994,938 | 13,622,724 | 48,809,571 | 12,051,746 |
| **បែងចែកឱ្យ៖** | | | | | |
| ម្ចាស់ភាគហ៊ុនក្រុមហ៊ុន | | 54,994,938 | 13,622,724 | 48,809,571 | 12,051,746 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី 12 ដល់ទំព័រទី 55 គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

**អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី**

## របាយការណ៍បម្រែបម្រួលមូលធន
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

| | ដើមទុន<br>ពាន់រៀល | ទុនបម្រុង<br>ពាន់រៀល | ចំណេញរក្សាទុក<br>ពាន់រៀល | សរុប<br>ពាន់រៀល |
|---|---|---|---|---|
| គិតត្រឹមថ្ងៃទី01 ខែមករា ឆ្នាំ2015 | 23,368,200 | 3,695,520 | 69,927,976 | 96,991,696 |
| ផ្ទេរទៅទុនបម្រុង | - | 584,038 | (584,038) | - |
| ចំណេញក្នុងឆ្នាំ | - | - | 48,809,571 | 48,809,571 |
| **គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2015** | 23,368,200 | 4,279,558 | 118,153,509 | 145,801,267 |
| **គិតជាដុល្លារអាមេរិក** | 5,769,926 | 1,056,681 | 29,173,705 | 36,000,312 |
| | | | | |
| គិតត្រឹមថ្ងៃទី01 ខែមករា ឆ្នាំ2016 | 23,368,200 | 4,279,558 | 118,153,509 | 145,801,267 |
| ភាគលាភបានបង់ | - | - | (4,881,617) | (4,881,617) |
| ផ្ទេរទៅទុនបម្រុង | - | 582,164 | (582,164) | - |
| ចំណេញក្នុងឆ្នាំ | - | - | 54,994,938 | 54,994,938 |
| **គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2016** | 23,368,200 | 4,861,722 | 167,684,666 | 195,914,588 |
| **គិតជាដុល្លារអាមេរិក** | 5,788,506 | 1,204,291 | 41,536,950 | 48,529,747 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី 12 ដល់ទំព័រទី 55 គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## របាយការណ៍លំហូរសាច់ប្រាក់
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

| | កំណត់ | 2016 | | 2015 | |
|---|---|---|---|---|---|
| | សម្គាល់ | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ | | 68,931,021 | 17,074,813 | 61,144,991 | 15,097,528 |
| *និយ័តកម្ម ៖* | | | | | |
| រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ | 9 | 3,584,159 | 887,827 | 2,223,346 | 548,974 |
| រំលស់ទ្រព្យសកម្មអរូបី | 10 | 20,699 | 5,128 | 19,309 | 4,768 |
| សំវិធានធនឥណទានអាក្រក់និងសង្ស័យ | 7 | 14,989,712 | 3,713,082 | 1,952,391 | 482,072 |
| បង្គរផ្សេងៗ | | 3,416,578 | 846,316 | 1,149,086 | 283,725 |
| ចំណេញពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | 19 | (50,391) | (12,482) | (28,427) | (7,019) |
| ចំណូលការប្រាក់សុទ្ធ | | (154,471,571) | (38,263,951) | (119,323,832) | (29,462,675) |
| | | (63,579,793) | (15,749,267) | (52,863,136) | (13,052,627) |
| *បម្រែបម្រួលដើមទុនបង្វិល* | | | | | |
| ប្រាក់បញ្ញើបម្រុងនៅធនាគារកណ្តាល | | (7,865,169) | (1,948,271) | (1,266,441) | (312,701) |
| សមតុល្យនៅធនាគារកណ្តាល | | 2,450,051 | 606,899 | (2,450,051) | (604,951) |
| សមតុល្យនៅធនាគារផ្សេងៗ | | 38,751,750 | 9,599,145 | 6,028,306 | 1,488,471 |
| ឥណទានអតិថិជន | | (131,292,591) | (32,522,316) | (293,900,606) | (72,568,051) |
| ទ្រព្យសកម្មផ្សេងៗ | | 2,476,652 | 613,488 | (7,002,331) | (1,728,971) |
| ប្រាក់បញ្ញើរបស់គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | | 24,222,052 | 6,000,014 | - | - |
| ប្រាក់បញ្ញើអតិថិជន | | 52,786,132 | 13,075,584 | 1,114,636 | 275,219 |
| បំណុលផ្សេងៗ | | 695,915 | 172,384 | 5,051,473 | 1,247,277 |
| សាច់ប្រាក់បានប្រើក្នុងប្រតិបត្តិការ | | (81,355,001) | (20,152,340) | (345,288,150) | (85,256,334) |
| ចំណូលការប្រាក់បានទទួល | | 225,476,321 | 55,852,445 | 164,343,104 | 40,578,544 |
| ចំណាយការប្រាក់បានបង់ | | (69,148,431) | (17,128,668) | (45,489,323) | (11,231,932) |
| ពន្ធលើប្រាក់ចំណេញបានបង់ | 11(b.i) | (12,889,230) | (3,192,774) | (8,255,882) | (2,038,489) |
| សាច់ប្រាក់បានពី/(បានប្រើក្នុង)សកម្មភាពប្រតិបត្តិការ | | 62,083,659 | 15,378,663 | (234,690,251) | (57,948,211) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ទិញទ្រព្យសម្បត្តិ និងបរិក្ខារ | 9 | (6,554,761) | (1,623,671) | (3,619,131) | (893,613) |
| ទិញទ្រព្យសកម្មអរូបី | 10 | (2,298,578) | (569,378) | (10,283) | (2,539) |
| សាច់ប្រាក់បានពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | | 71,087 | 17,609 | 37,515 | 9,263 |
| សាច់ប្រាក់បានប្រើក្នុងសកម្មភាពវិនិយោគ | | (8,782,252) | (2,175,440) | (3,591,899) | (886,889) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់បានពីប្រាក់កម្ចី | | 312,374,435 | 77,377,864 | 573,768,811 | 141,671,311 |
| សងប្រាក់កម្ចី | | (321,231,436) | (79,571,820) | (275,598,477) | (68,049,007) |
| ភាគលាភបានបង់ | | (4,881,617) | (1,209,219) | - | - |
| សាច់ប្រាក់បានប្រើក្នុងសកម្មភាពហិរញ្ញប្បទាន | | (13,738,618) | (3,403,175) | 298,170,334 | 73,622,304 |
| **កំណើនសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | 39,562,789 | 9,800,048 | 59,888,184 | 14,787,204 |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមឆ្នាំ | | 61,007,430 | 15,063,562 | 1,119,246 | 274,662 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | 48,507 | - | 1,696 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងឆ្នាំ** | 23 | 100,570,219 | 24,912,117 | 61,007,430 | 15,063,562 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី 12 ដល់ទំព័រទី 55 គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

**អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី**

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016**

## 1. ព័ត៌មានទូទៅ

ធនាគារ ភូមិ (ខេមបូឌា) អិលធីឌី (ហៅកាត់ថា "ក្រុមហ៊ុន") ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ បានចុះបញ្ជីពាណិជ្ជកម្មនៅប្រទេសកម្ពុជា និងបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត ក្រោមវិញ្ញាបនបត្រចុះបញ្ជីលេខ Co. 1413E/2002 ចុះថ្ងៃទី23 ខែឧសភា ឆ្នាំ2002 និងបានបន្តអាជ្ញាប័ណ្ណថ្មីនៅថ្ងៃទី28 ខែកញ្ញា ឆ្នាំ2015។ បន្ទាប់ពីការផ្លាស់ប្តូរចនាសម្ព័ន្ធភាគទុនិក នៅខែកញ្ញា ឆ្នាំ2014 ក្រុមហ៊ុនក្លាយជាបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន LOLC Micro Investments Ltd ដែលបានចុះបញ្ជីពាណិជ្ជកម្មនៅប្រទេសស្រីលង្កា។ ក្រុមហ៊ុនមេធំជាងគេគឺក្រុមហ៊ុន Lanka ORIX Leasing Company PLC ជាក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្មនៅប្រទេសស្រីលង្កា និងបានចុះបញ្ជីនៅក្នុងក្រុមហ៊ុនមូលបត្រកូឡុមបូ។

សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាមីក្រូហិរញ្ញវត្ថុ (ទទួលប្រាក់បញ្ញើ និងផ្តល់កម្ចី) ដល់ប្រជាពលរដ្ឋនៅតាមជនបទ និងសហគ្រាសខ្នាតតូច តាមរយៈទីស្នាក់ការកណ្តាលរបស់ខ្លួននៅរាជធានីភ្នំពេញ និងសាខានៅតាមបណ្តាខេត្តមួយចំនួនទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ គោលដៅអាជីវកម្មរបស់ក្រុមហ៊ុន គឺផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលមានភាពជឿទុកចិត្ត និងដែលអាចទទួលយកបានដល់សហគ្រិនខ្នាតតូច។

នៅថ្ងៃទី09 ខែកក្កដា ឆ្នាំ2015 ធនាគារជាតិ នៃ កម្ពុជា បានអនុម័តការប្តូរនាមករណ៍ក្រុមហ៊ុនពី ធនាគារភូមិ (ខេមបូឌា) អិលធីឌី ទៅជា អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី វិញ ហើយការប្តូរនាមករណ៍ក្រុមហ៊ុននេះ ត្រូវបានបញ្ជាក់នៅក្នុងឯកសារស្របច្បាប់ផ្សេងៗរបស់ក្រុមហ៊ុន រួមទាំងលក្ខន្តិកៈក្រុមហ៊ុនចុះថ្ងៃទី12 ខែសីហា ឆ្នាំ2015 និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មចុះថ្ងៃទី30 ខែកញ្ញា ឆ្នាំ2015 ផងដែរ។

ធនាគារជាតិ នៃ កម្ពុជា (ហៅកាត់ថា "ធនាគារកណ្តាល") បានផ្តល់អាជ្ញាប័ណ្ណរយៈពេលបីឆ្នាំឱ្យក្រុមហ៊ុន ដើម្បីធ្វើប្រតិបត្តិការអាជីវកម្មជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មានសុពលភាពចាប់ពីថ្ងៃទី12 ខែកុម្ភៈ ឆ្នាំ2003 ដល់ថ្ងៃទី12 ខែកុម្ភៈ ឆ្នាំ2006។ នៅថ្ងៃទី20 ខែមករា ឆ្នាំ2006 ធនាគារជាតិ នៃ កម្ពុជា បានផ្តល់អាជ្ញាប័ណ្ណបន្តរយៈពេលបីឆ្នាំទៀត ចាប់ពីថ្ងៃទី12 ខែកុម្ភៈ ឆ្នាំ2006 ដល់ថ្ងៃទី12 ខែកុម្ភៈ ឆ្នាំ2009។ នៅថ្ងៃទី14 ខែមករា ឆ្នាំ2009 ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណអចិន្ត្រៃយ៍ពីធនាគារកណ្តាល។

ជាងនេះទៅទៀត នៅថ្ងៃទី11 ខែកញ្ញា ឆ្នាំ2015 ក្រុមហ៊ុនទទួលបានអាជ្ញាប័ណ្ណលេខ M.F 04 ជាផ្លូវការពីធនាគារកណ្តាល ដើម្បីប្រកបអាជីវកម្មទទួលប្រាក់បញ្ញើ។

ក្រុមហ៊ុនមានការិយាល័យចំនួន 73 ការិយាល័យ (ការិយាល័យសាខាចំនួន 72 ការិយាល័យ និងទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ)។ ទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុនមានទីតាំងស្ថិតនៅ ផ្ទះលេខ 666B ផ្លូវលេខ 271 សង្កាត់ ផ្សារដើមថ្កូវ ខណ្ឌ ចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

ក្រុមប្រឹក្សាភិបាលបានអនុម័តឱ្យចេញផ្សាយរបាយការណ៍ហិរញ្ញវត្ថុនេះ នៅថ្ងៃទី05 ខែមេសា ឆ្នាំ2017។

## 2. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ

គោលការណ៍គណនេយ្យសំខាន់ៗ ដែលបានប្រើប្រាស់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញខាងក្រោម។ គោលការណ៍គណនេយ្យទាំងនេះ ត្រូវបានអនុវត្តយ៉ាងស៊ីសង្វាក់គ្រប់ឆ្នាំទាំងអស់ដែលបានបង្ហាញ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

### 2.1 មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលបានបង្ហាញជាប្រាក់រៀល ត្រូវបានរៀបចំឡើងតាមវិធីសាស្ត្រថ្លៃដើម និងស្របទៅតាមស្តង់ដារគណនេយ្យកម្ពុជា (ហៅកាត់ថា "CAS") និងគោលការណ៍ណែនាំរបស់ធនាគារកណ្តាល។

គោលការណ៍គណនេយ្យដែលបានប្រើប្រាស់ អាចមានភាពខុសគ្នាពីគោលការណ៍គណនេយ្យដែលត្រូវបានទទួលស្គាល់ និងប្រើប្រាស់ជាទូទៅនៅតាមបណ្តាប្រទេស និងយុត្តាធិការផ្សេងៗ។ របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយនេះ មិនមានបំណងបង្ហាញអំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់ ដោយអនុលោមទៅតាមយុត្តាធិការណាផ្សេងក្រៅពីព្រះរាជាណាចក្រកម្ពុជានោះទេ។ ដូចនេះរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ សម្រាប់បង្ហាញចំពោះតែអ្នកដែលបានជ្រាបអំពីគោលការណ៍គណនេយ្យ នីតិវិធី និងការអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលស្របទៅតាមស្តង់ដារគណនេយ្យកម្ពុជា តម្រូវឱ្យប្រើប្រាស់ការប៉ាន់ស្មាន និងការសន្មត ដែលមានផលប៉ះពាល់ដល់ចំនួនទ្រព្យសកម្ម និងបំណុល និងការលាតត្រដាងទ្រព្យសកម្ម និងបំណុលយថាភាពដែលបានរាយការណ៍ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុ និងប៉ះពាល់ដល់ចំណូល និងចំណាយដែលបានរាយការណ៍នៅក្នុងអំឡុងពេលនៃការធ្វើរបាយការណ៍នេះ។ បើទោះជាការប៉ាន់ស្មានទាំងនេះ ផ្អែកទៅលើការយល់ដឹងដ៏សុក្រឹតរបស់គណៈគ្រប់គ្រងទៅលើព្រឹត្តិការណ៍ និងសកម្មភាពផ្សេងៗនាពេលបច្ចុប្បន្នក៏ដោយ ក៏លទ្ធផលជាក់លាក់ចុងក្រោយអាចខុសពីការប៉ាន់ស្មានទាំងនេះ។ ផ្នែកដែលទាក់ទងនឹងការវិនិច្ឆ័យ ឬភាពស្មុគស្មាញក្នុងកម្រិតខ្ពស់ ឬផ្នែកដែលការសន្មត និងការប៉ាន់ស្មានមានលក្ខណៈជាសារវន្តចំពោះរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ 3។

### 2.2 ស្តង់ដារគណនេយ្យហិរញ្ញវត្ថុ

នៅថ្ងៃទី28 ខែសីហា ឆ្នាំ2009 ក្រុមប្រឹក្សាជាតិគណនេយ្យនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានប្រកាសដាក់ឱ្យប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា (ហៅកាត់ថា "CIFRS") ដែលផ្អែកទាំងស្រុងទៅតាមស្តង់ដារទាំងអស់ដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ រួមទាំងបំណកស្រាយ និងវិសោធនកម្មពាក់ព័ន្ធផ្សេងៗដែលអាចកើតមានក្នុងកាលៈទេសៈនានាចំពោះស្តង់ដារនីមួយៗ ដោយគ្រាន់តែបន្ថែមពាក្យ "កម្ពុជា"។ អង្គភាពដែលមានការទទួលខុសត្រូវជាសាធារណៈ ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនឱ្យស្របទៅតាម CIFRS សម្រាប់ការិយបរិច្ឆេទគណនេយ្យដែលចាប់ផ្តើមនៅថ្ងៃទី01 ខែមករា ឆ្នាំ2012 ឬការិយបរិច្ឆេទគណនេយ្យបន្ទាប់ពីនេះ។

សារាចរណែនាំលេខ 086 សហវ-កជគ ចុះថ្ងៃទី30 ខែកក្កដា ឆ្នាំ2012 ក្រុមប្រឹក្សាជាតិគណនេយ្យ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានអនុញ្ញាតឱ្យធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុពន្យារពេលអនុវត្ត CIFRS រហូតដល់ការិយបរិច្ឆេទដែលចាប់ផ្តើមនៅថ្ងៃទី01 ខែមករា ឆ្នាំ2019 ឬការិយបរិច្ឆេទបន្ទាប់ពីនេះ។

CAS ស្តង់ដារគណនេយ្យដែលក្រុមហ៊ុនកំពុងប្រើប្រាស់បច្ចុប្បន្ន មានភាពខុសប្លែកគ្នាជាច្រើនផ្នែក បើធៀបនឹង CIFRS។ ដូច្នេះ ការអនុវត្ត CIFRS នឹងមានផលប៉ះពាល់មួយចំនួនទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## 2. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

## 2.3 ការប្តូររូបិយប័ណ្ណ

*(ក) រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ*

គណនីទាំងអស់ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានវាស់តម្លៃដោយប្រើរូបិយប័ណ្ណនៃបរិយាកាសសេដ្ឋកិច្ចចម្បងដែលក្រុមហ៊ុនធ្វើប្រតិបត្តិការ (ហៅកាត់ថា "រូបិយប័ណ្ណគោល")។ ក្រុមហ៊ុនរក្សាទុកកំណត់ត្រាគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនជាប្រាក់រៀល ដែលជារូបិយប័ណ្ណគោលរបស់ក្រុមហ៊ុន។ របាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញជាប្រាក់រៀលដែលជារូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញរបស់ក្រុមហ៊ុន។

*(ខ) ប្រតិបត្តិការ និងសមតុល្យ*

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់រៀលដែលជារូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ ត្រូវបានកត់ត្រាប្តូរទៅជាប្រាក់រៀល តាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញនិងខាតពីការប្តូររូបិយប័ណ្ណដែលបណ្តាលមកពីការទូទាត់តាមប្រតិបត្តិការបែបនេះ និងពីការប្តូរទ្រព្យសកម្មនិងបំណុលរូបិយវត្ថុនានាដែលកំណត់ជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់រៀលតាមអត្រាប្តូរប្រាក់នាដំណាច់ឆ្នាំ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល។

*(គ) ការបង្ហាញជាប្រាក់ដុល្លារអាមេរិក*

ការកត់ត្រាប្តូរប្រាក់រៀលទៅជាប្រាក់ដុល្លារអាមេរិក (US$) ត្រូវបានធ្វើឡើងសម្រាប់គណៈគ្រប់គ្រងប្រើប្រាស់តែប៉ុណ្ណោះ និងផ្អែកទៅតាមអត្រាប្តូរប្រាក់ផ្លូវការដែលផ្សព្វផ្សាយដោយធនាគារកណ្តាល នាកាលបរិច្ឆេទរបាយការណ៍។ តួលេខដែលបានប្តូរនេះមិនត្រូវបានធ្វើសវនកម្មទេ ហើយមិនគួរបកស្រាយថា តួលេខនេះជាតួលេខសម្រាប់បង្ហាញ ដូចតួលេខជាប្រាក់រៀល ឬយល់ថាជាតួលេខត្រូវបានប្តូរ ឬអាចប្តូរទៅជាប្រាក់ដុល្លារអាមេរិកតាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតទេ។

| | **ថ្ងៃទី31 ខែធ្នូ ឆ្នាំ2016** | **ថ្ងៃទី31 ខែធ្នូ ឆ្នាំ2015** |
|---|---|---|
| ប្រាក់រៀល/ដុល្លារអាមេរិក | 4,037 | 4,050 |

## 2.4 មូលដ្ឋាននៃការសរុបរួម

របាយការណ៍ហិរញ្ញវត្ថុនេះ រួមបញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ទីស្នាក់ការកណ្តាល និងរបាយការណ៍ហិរញ្ញវត្ថុរបស់បណ្តាសាខានានា ក្រោយពីលុបចោលនូវរាល់សមតុល្យ និងប្រតិបត្តិការអន្តរសាខាសំខាន់ៗ។

## 2.5 សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់ក្នុងដៃ សមតុល្យគ្មានកំហិតនៅធនាគារកណ្តាល ប្រាក់បញ្ញើនៅធនាគារ ការវិនិយោគសាច់ប្រាក់ងាយស្រួលរយៈពេលខ្លី ដែលមានកាលកំណត់ដើមរយៈពេលបីខែ ឬតិចជាងបីខែ គិតចាប់ពីថ្ងៃដែលក្រុមហ៊ុនមានលទ្ធភាពពេញលេញ ក្នុងការដកសាច់ប្រាក់នោះមកប្រើប្រាស់តាមតម្រូវការទូទៅ។

ឥណទានវិបារូបន៍ ត្រូវបានបង្ហាញនៅក្នុងបំណុលលើតារាងតុល្យការ ។

## 2. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### 2.6 ឥណទានអតិថិជន

ឥណទានអតិថិជនត្រូវបានរាយការណ៍ក្នុងតារាងតុល្យការ តាមចំនួនទឹកប្រាក់ដើម ដកចំនួនដែលបានជម្រះចេញពីបញ្ជី និងសំវិធានធនឥណទានអាក្រក់ និងសង្ស័យ។

ឥណទានត្រូវបានជម្រះចេញពីបញ្ជី នៅពេលដែលមិនមានភាពប្រាកដថា នឹងអាចប្រមូលប្រាក់មកវិញបាន។

### 2.7 សំវិធានធនឥណទានអាក្រក់ និងសង្ស័យ

គណៈគ្រប់គ្រងវាយតម្លៃប្រចាំខែ អំពីភាពគ្រប់គ្រាន់នៃសំវិធានធនឥណទានអាក្រក់ និងសង្ស័យ។

ក្រុមហ៊ុនបានអនុវត្តការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន តាមតម្រូវការរបស់ប្រកាសលេខ ធ7-02-186 ប្រ.ក. ចុះថ្ងៃទី13 ខែកញ្ញា ឆ្នាំ2002។ ប្រកាសនេះតម្រូវឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធ្វើចំណាត់ថ្នាក់ឥណទានរបស់ខ្លួនជាបួនចំណាត់ថ្នាក់ដូចខាងក្រោម ហើយត្រូវប្រាកដថាក្រុមហ៊ុនបានកត់ត្រាកម្រិតអប្បបរមានៃសំវិធានធនជាក់លាក់។

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃផុតកំណត់ | សំវិធានធន |
|---|---|---|
| *ឥណទានរយៈពេលខ្លី (តិចជាងមួយឆ្នាំ):* | | |
| ស្តង់ដារ | 0 - 29 ថ្ងៃ | 0% |
| ក្រោមស្តង់ដារ | 30 - 59 ថ្ងៃ | 10% |
| សង្ស័យ | 60 - 89 ថ្ងៃ | 30% |
| បាត់បង់ | លើសពី 90 ថ្ងៃឡើងទៅ | 100% |
| *ឥណទានរយៈពេលវែង (លើសពីមួយឆ្នាំឡើងទៅ):* | | |
| ស្តង់ដារ | 0 - 29 ថ្ងៃ | 0% |
| ក្រោមស្តង់ដារ | 30 - 179 ថ្ងៃ | 10% |
| សង្ស័យ | 180 - 359 ថ្ងៃ | 30% |
| បាត់បង់ | លើសពី 360 ថ្ងៃឡើងទៅ | 100% |

សំវិធានធនជាក់លាក់ត្រូវបានគណនាតាមភាគរយនៃឥណទាននៅសល់ នៅពេលដែលឥណទានត្រូវបានធ្វើចំណាត់ថ្នាក់ ហើយត្រូវបានកត់ត្រាជាចំណាយនៅក្នុងរបាយការណ៍លទ្ធផល ។

ក្រុមហ៊ុនកត់ត្រាសំវិធានធន 100% សម្រាប់ឥណទានបាត់បង់ ដែលផុតកាលកំណត់សង 30ថ្ងៃ ឬលើសពីនេះ។ ចំនួនសំវិធានធនដែលលើសកម្រិតភាគរយតម្រូវដោយធនាគារកណ្តាល ត្រូវបានបង្ហាញជាសំវិធានធនទូទៅ។

ឥណទានត្រូវបានជម្រះចេញពីបញ្ជី នៅពេលដែលឥណទានទាំងនោះ មិនអាចប្រមូលមកវិញបាន។ ឥណទានដែលបានជម្រះចេញពីបញ្ជី ត្រូវបានកាត់ចេញពីឥណទានដែលនៅសល់ និងពីសំវិធានធនឥណទានបាត់បង់។

ការប្រមូលបានមកវិញនូវឥណទានដែលបានជម្រះចេញពីបញ្ជីក្នុងគ្រាមុន ត្រូវបានលាតត្រដាងជាចំណូលប្រតិបត្តិការ នៅក្នុងរបាយការណ៍លទ្ធផល។

## 2. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### 2.8 ទ្រព្យសម្បត្តិ និងបរិក្ខារ

ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់បង្គរ និងការខាតបង្គរដែលបណ្តាលមកពីការចុះថយតម្លៃ។ ថ្លៃដើមរួមមានចំណាយផ្ទាល់ផ្សេងៗក្នុងការនាំយកទ្រព្យសម្បត្តិនោះ មកកាន់ទីតាំង និងលក្ខខណ្ឌចាំបាច់ ដើម្បីឱ្យវាអាចធ្វើប្រតិបត្តិការទៅតាមការគ្រោងទុករបស់គណៈគ្រប់គ្រង។

ចំណាយបន្តបន្ទាប់ផ្សេងៗត្រូវបានកត់ត្រាបញ្ចូលទៅក្នុងតម្លៃយោងនៃទ្រព្យនោះ ឬត្រូវបានកត់ត្រាជាទ្រព្យសកម្មដាច់ដោយឡែក តាមការសមស្រប តែនៅពេលដែលមានភាពប្រាកដថា ផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតនៃទ្រព្យនោះនឹងហូរចូលមកក្នុងក្រុមហ៊ុន ហើយថ្លៃដើមនៃទ្រព្យនោះ អាចត្រូវបានវាស់វែងគួរឱ្យជឿជាក់បានតែប៉ុណ្ណោះ។ ចំណាយលើការជួសជុល និងការថែទាំផ្សេងៗទៀតទាំងអស់ ត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងរបាយការណ៍លទ្ធផល ក្នុងការិយបរិច្ឆេទដែលប្រតិបត្តិការនោះបានកើតឡើង។

ការធ្វើរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងរបាយការណ៍លទ្ធផល តាមវិធីសាស្ត្ររំលស់ថេរតាមអត្រាកំណត់ដូចខាងក្រោម ៖

| **ប្រភេទ** | **អាយុកាលប្រើប្រាស់** |
|---|---|
| គ្រឿងសង្ហារិម និងបរិក្ខារការិយាល័យ | 3 – 5 ឆ្នាំ |
| យានយន្ត | 4 – 5 ឆ្នាំ |
| បរិក្ខារកុំព្យូទ័រ | 3 ឆ្នាំ |
| ការកែលម្អទ្រព្យជួល | រយៈពេលមួយណាដែលតិចជាងគេ រវាងអាយុកាលសេដ្ឋកិច្ចរបស់ទ្រព្យនោះ និងថេរវេលានៃកិច្ចសន្យាជួល |

តម្លៃសំណល់ អាយុកាលប្រើប្រាស់ និងវិធីសាស្ត្ររំលស់របស់ទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យ និងធ្វើនិយ័តកម្មតាមការសមស្រប ប្រសិនបើមានសញ្ញាណនៃការប្រែប្រួលជាសារវន្តណាមួយ ចាប់តាំងពីកាលបរិច្ឆេទរបាយការណ៍មុនមក។

តម្លៃយោងនៃទ្រព្យសកម្មណាមួយ ដែលលើសពីតម្លៃដែលអាចស្រង់មកវិញបានរបស់វា ត្រូវបានកត់ត្រាបន្ថយភ្លាមឱ្យនៅត្រឹមតម្លៃប៉ាន់ស្មានដែលអាចស្រង់មកវិញបាន។

ចំណេញ ឬខាតពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកត់ត្រានៅពេលលក់ទ្រព្យនោះចេញ។

ទ្រព្យសម្បត្តិ និងបរិក្ខារដែលអស់រំលស់ទាំងស្រុង ត្រូវបានរក្សាទុកនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ រហូតដល់ពេលដែលទ្រព្យនោះត្រូវបានលក់ចេញ ឬជម្រះចេញពីបញ្ជី។

### 2.9 ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបីដែលរួមមានអាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រដែលបានទិញ និងចំណាយពាក់ព័ន្ធផ្សេងៗ ត្រូវបានរាយការណ៍តាមថ្លៃដើម ដករំលស់បង្គរ និងការខាតដែលបណ្តាលមកពីការថយចុះតម្លៃ។ អាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រដែលបានទិញត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើមដែលបានកើតឡើងក្នុងការទិញកម្មវិធីជាក់លាក់នោះមកប្រើប្រាស់។ ទ្រព្យសកម្មអរូបីត្រូវបានធ្វើរំលស់លើអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់វារយៈពេលប្រាំឆ្នាំ ដោយប្រើប្រាស់វិធីសាស្ត្ររំលស់ថេរ។

ចំណាយនានាពាក់ព័ន្ធនឹងការថែរក្សាកម្មវិធីកុំព្យូទ័រ ត្រូវបានកត់ត្រាជាចំណាយ នៅពេលដែលប្រតិបត្តិការនោះបានកើតឡើង។

## 2. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### 2.10 ការថយចុះតម្លៃ នៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ទ្រព្យសកម្មដែលមានអាយុកាលប្រើប្រាស់មិនកំណត់ មិនត្រូវបានធ្វើរំលស់ទេ និងត្រូវបានត្រួតពិនិត្យប្រចាំឆ្នាំដើម្បីរកការថយចុះតម្លៃរបស់វា។ ទ្រព្យសកម្មទាំងឡាយណាដែលត្រូវបានធ្វើរំលស់ ត្រូវបានត្រួតពិនិត្យរកការថយចុះតម្លៃរបស់វា នៅពេលដែលមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈណាមួយចង្អុលបង្ហាញថាតម្លៃយោងរបស់វា នឹងមិនអាចយកមកវិញបាន។ ការខាតបង់បណ្តាលមកពីការថយចុះតម្លៃ ត្រូវបានកត់ត្រាតាមចំនួនលម្អៀងរវាងតម្លៃយោងនៃទ្រព្យនោះ ធៀបជាមួយតម្លៃដែលអាចយកមកវិញបាន។ តម្លៃដែលអាចយកមកវិញបាន គឺជាតម្លៃមួយណាដែលខ្ពស់ជាងគេ រវាងតម្លៃសមស្របនៃទ្រព្យនោះដកចំណាយក្នុងការលក់ និងតម្លៃនៅប្រើប្រាស់។ ក្នុងការវាយតម្លៃរកការថយចុះតម្លៃ ទ្រព្យសកម្មត្រូវបានបែងចែកជាក្រុមតូចៗបំផុត ដើម្បីកំណត់ពីលំហូរសាច់ប្រាក់របស់វានីមួយៗ (ឯកតាបង្កើតសាច់ប្រាក់)។

### 2.11 ប្រាក់កម្ចី

ប្រាក់កម្ចីត្រូវបានកត់ត្រាតាមចំនួនប្រាក់ដើម ដែលមិនទាន់ទូទាត់។ សោហ៊ុយផ្សេងៗដែលបានចំណាយដើម្បីទទួលបានប្រាក់កម្ចី ត្រូវបានធ្វើរំលស់តាមមូលដ្ឋានរំលស់ថេរ លើរយៈពេលនៃប្រាក់កម្ចី នៅក្នុងរបាយការណ៍លទ្ធផល។

ចំណាយលើប្រាក់កម្ចី (ចំណាយការប្រាក់) ត្រូវបានកត់ត្រាជាចំណាយ នៅក្នុងឆ្នាំដែលចំណាយនោះបានកើតឡើង លើកលែងតែចំណាយផ្ទាល់ទៅលើការទិញ ការសាងសង់ ឬការផលិតទ្រព្យសកម្មដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវបានធ្វើមូលធនកម្មទៅជាផ្នែកមួយនៃថ្លៃដើមរបស់ទ្រព្យនោះ។ ការធ្វើមូលធនកម្មប្រាក់កម្ចីនឹងត្រូវបញ្ឈប់ នៅពេលដែលសកម្មភាពចាំបាច់ទាំងអស់ក្នុងការរៀបចំទ្រព្យនោះសម្រាប់ប្រើប្រាស់តាមការគ្រោងទុក ឬសម្រាប់លក់ ត្រូវបានបញ្ចប់។

### 2.12 អនុបំណុល

អនុបំណុលត្រូវបានចាត់ទុកជាបំណុលហិរញ្ញវត្ថុ នៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចតាមកិច្ចសន្យា ដើម្បីប្រគល់សាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុ ទៅឱ្យអង្គភាពមួយផ្សេងទៀត ឬដើម្បីផ្លោះប្តូរទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុជាមួយអង្គភាពមួយផ្សេងទៀត ក្រោមលក្ខខណ្ឌដែលមិនសូវអំណោយផលចំពោះក្រុមហ៊ុន ហើយប្រសិនបើវាមានភាពអំណោយផលចំពោះក្រុមហ៊ុន វានឹងត្រូវចាត់ទុកជាមូលធន។ អនុបំណុលដែលត្រូវបានអនុម័តដោយធនាគារកណ្តាល ត្រូវបានរាប់បញ្ចូលទៅក្នុងដើមទុនថ្នាក់ទី2 ក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ក្រុមហ៊ុន អនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារកណ្តាល។

## 2. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### 2.13 សំវិធានធនសម្រាប់បំណុល និងចំណាយផ្សេងៗ

សំវិធានធនត្រូវបានកត់ត្រានៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោល ដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល ដែលទំនងជាអាចតម្រូវឱ្យមានការចំណាយធនធានដើម្បីទូទាត់កាតព្វកិច្ចនោះ ហើយចំនួនទឹកប្រាក់ត្រូវបានប៉ាន់ស្មានគួរឱ្យជឿជាក់បាន។

នៅពេលដែលមានកាតព្វកិច្ចស្រដៀងគ្នាច្រើន កម្រិតនៃលំហូរចេញដើម្បីទូទាត់កាតព្វកិច្ចនោះត្រូវបានកំណត់ដោយគិតទៅលើចំណាត់ថ្នាក់នៃកាតព្វកិច្ចនោះទាំងមូល។ សំវិធានធនត្រូវបានកត់ត្រាទោះបីជាកម្រិតលំហូរចេញនៃខ្ទង់ណាមួយនៅក្នុងចំណាត់ថ្នាក់កាតព្វកិច្ចដូចគ្នានោះ មានចំនួនតូចក៏ដោយ។

សំវិធានធនត្រូវបានវាស់វែងឡើងវិញតាមតម្លៃបច្ចុប្បន្ននៃចំណាយ ដែលរំពឹងថាត្រូវទូទាត់កាតព្វកិច្ចនោះ ដោយប្រើអត្រាមុនបង់ពន្ធ ដើម្បីឆ្លុះបញ្ចាំងការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃសាច់ប្រាក់គិតតាមពេលវេលា និងហានិភ័យជាក់លាក់ផ្សេងៗនៃកាតព្វកិច្ចនោះ។ ការកើនឡើងសំវិធានធនដោយសារពេលវេលាដែលបានកន្លងផុត ត្រូវបានកត់ត្រាជាចំណាយការប្រាក់។

### 2.14 ការកត់ត្រាចំណូល និងចំណាយការប្រាក់

ចំណូលការប្រាក់បានមកពីឥណទានអតិថិជន សមតុល្យនៅធនាគារកណ្តាល និងសមតុល្យនៅធនាគារផ្សេងៗ ត្រូវបានកត់ត្រាតាមមូលដ្ឋានបង្គរ។ នៅពេលដែលឥណទានអតិថិជនក្លាយជាឥណទានមិនដំណើរការ (ហួសកាលកំណត់លើសពី30ថ្ងៃឡើងទៅ) ការកត់ត្រាចំណូលការប្រាក់ពីឥណទានអតិថិជន ត្រូវបានព្យួរទុកមួយរយៈ រហូតដល់ពេលទទួលបានសាច់ប្រាក់ជាក់ស្តែង។

ចំណាយការប្រាក់លើប្រាក់កម្ចី និងអនុបំណុល ត្រូវបានកត់ត្រាតាមមូលដ្ឋានបង្គរ។

### 2.15 ចំណូលកម្រៃជើងសារពីឥណទាន

ជាទូទៅ ចំណូលកម្រៃជើងសារត្រូវបានកត់ត្រាតាមមូលដ្ឋានបង្គរ នៅពេលដែលក្រុមហ៊ុនបានបំពេញសេវាជូនអតិថិជនរួច។ ចំណូលកម្រៃជើងសាររួមមាន ចំណូលដែលបានទទួលពីសេវាផ្តល់ឥណទានជូនអតិថិជន។

### 2.16 ភតិសន្យា

ភតិសន្យាប្រតិបត្តិដែលភាគីម្ចាស់ទ្រព្យនៅមានហានិភ័យជាក់លាក់ និងកម្មសិទ្ធិលើទ្រព្យនោះ ត្រូវបានចាត់ថ្នាក់ជាភតិសន្យាប្រតិបត្តិ។ ការទូទាត់ភតិសន្យាប្រតិបត្តិ (កាត់កងនឹងការលើកទឹកចិត្តផ្សេងៗ ដែលទទួលបានពីភាគីម្ចាស់ទ្រព្យ) ត្រូវបានកត់ត្រាជាបន្ទុកក្នុងរបាយការណ៍លទ្ធផល តាមមូលដ្ឋានថេរលើរយៈពេលនៃភតិសន្យា។

## 2. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### 2.17 ប្រតិបត្តិការភាគីពាក់ព័ន្ធ

ភាគីដែលត្រូវបានចាត់ទុកថាមានការពាក់ព័ន្ធ ប្រសិនបើភាគីនោះមានលទ្ធភាពដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ក្នុងការគ្រប់គ្រងភាគីមួយផ្សេងទៀត ឬមានឥទ្ធិពលជាសារវន្តលើភាគីមួយផ្សេងទៀត ក្នុងការសម្រេចចិត្តលើផ្នែកប្រតិបត្តិការ និងហិរញ្ញវត្ថុ ឬប្រសិនបើក្រុមហ៊ុននិងភាគីនោះស្ថិតនៅក្រោមការគ្រប់គ្រងរួម ឬស្ថិតនៅ ក្រោមឥទ្ធិពលរួមរបស់ក្រុមហ៊ុនមេតែមួយ។ ភាគីពាក់ព័ន្ធអាចជាឯកបុគ្គលឬជាក្រុមហ៊ុន រាប់ទាំងសមាជិកគ្រួសារជិតដិតរបស់បុគ្គលនោះ ក៏ត្រូវបានចាត់ទុកជាភាគីពាក់ព័ន្ធដែរ។

អនុលោមតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ភាគីពាក់ព័ន្ធត្រូវបានឱ្យនិយមន័យថាជាភាគីទាំងឡាយណាដែលកាន់កាប់ដោយផ្ទាល់ឬដោយប្រយោល យ៉ាងហោចណាស់10%នៃដើមទុនរបស់ក្រុមហ៊ុន ឬមានសិទ្ធិបោះឆ្នោត រួមទាំងឯកបុគ្គលដែលមានតួនាទីក្នុងអភិបាលកិច្ច ការដឹកនាំ ការគ្រប់គ្រង ឬការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុន។

### 2.18 ពន្ធពន្យារលើប្រាក់ចំណេញ

បន្ទុកពន្ធលើប្រាក់ចំណេញក្នុងគ្រា ត្រូវបានគណនាតាមមូលដ្ឋានច្បាប់ពន្ធដារដែលបានអនុម័តរួចជាស្ថាពរ ឬបានអនុម័តរួចមួយផ្នែកធំ គិតត្រឹមកាលបរិច្ឆេទរបាយការណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា ជាទីកន្លែងដែលក្រុមហ៊ុនធ្វើប្រតិបត្តិការ និងបង្កើតប្រាក់ចំណេញជាប់ពន្ធ។

ពន្ធពន្យារត្រូវបានគណនាដោយប្រើវិធីសាស្រ្តបំណុលក្នុងតារាងតុល្យការ លើលម្អៀងបណ្តោះអាសន្ន នៃតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ធៀបនឹងចំនួនដែលបានប្រើប្រាស់សម្រាប់ការគណនាពន្ធ។ ពន្ធពន្យារត្រូវបានវាស់វែងតាមអត្រាពន្ធដែលរំពឹងថានឹងត្រូវអនុវត្តលើលម្អៀងបណ្តោះអាសន្ន នៅពេលដែលកត់ត្រាត្រឡប់ចូលមកវិញ ដោយផ្អែកតាមពន្ធដែលបានអនុម័តជាស្ថាពរ ឬបានអនុម័តរួចមួយផ្នែកធំ គិតត្រឹមកាលបរិច្ឆេទរបាយការណ៍។ ពន្ធពន្យារទ្រព្យសកម្មត្រូវបានកាត់កងជាមួយនឹងបំណុលពន្ធពន្យារ ប្រសិនបើក្រុមហ៊ុនមានសិទ្ធិតាមផ្លូវច្បាប់ដើម្បីទូទាត់បំណុលពន្ធ និងពន្ធទ្រព្យសកម្មក្នុងឆ្នាំ ហើយប្រសិនបើវាទាក់ទងនឹងពន្ធលើប្រាក់ចំណេញដែលកំណត់ដោយអាជ្ញាធរពន្ធដារតែមួយទៅលើអង្គភាពជាប់ពន្ធតែមួយ។

ពន្ធពន្យារទ្រព្យសកម្មត្រូវបានកត់ត្រា លុះត្រាតែមានភាពប្រាកដថាក្រុមហ៊ុននឹងមានប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត សម្រាប់យកលម្អៀងបណ្តោះអាសន្នមកប្រើប្រាស់។ ពន្ធពន្យារទ្រព្យសកម្មត្រូវបានត្រួតពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ ហើយត្រូវបានកត់ត្រាបន្ថយរហូតដល់កម្រិតមួយដែលមិនមានភាពប្រាកដថា នឹងមានអត្ថប្រយោជន៍ពន្ធពាក់ព័ន្ធនឹងត្រូវកើតឡើង។

### 2.19 ទុនបម្រុង

យោងតាមកិច្ចព្រមព្រៀងឥណទានដែលបានចុះហត្ថលេខារវាងក្រុមហ៊ុន និង Instituto De Crédito Ofical (ICO) នៃព្រះរាជាណាចក្រអេស្ប៉ាញ ក្នុងអំឡុងពេលនៃប្រាក់កម្ចីនេះ តម្រូវឱ្យក្រុមហ៊ុនផ្ទេរប្រាក់ស្មើនឹង3.5%នៃចំនួនប្រាក់កម្ចីដើមពី ICO ដែលនៅមិនទាន់ទូទាត់ ទៅក្នុងទុនបម្រុង ក្រោមកម្មវិធីមីក្រូហិរញ្ញវត្ថុរបស់ប្រទេសអេស្ប៉ាញ (Spanish Microfinance Program)។ ទុនបម្រុងនេះគឺសម្រាប់ពង្រឹងស្ថាប័ន និងត្រូវបានរក្សាទុកនៅក្នុងគណនីទុនបម្រុងផ្សេងៗ ទៅតាមអាយុកាលឥណទាន ឬបើមិនដូច្នោះទេ ត្រូវមានការយល់ព្រមពី ICO ។

## 2. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### 2.20 ភាគលាភ

ការបែងចែកភាគលាភជូនភាគទុនិករបស់ក្រុមហ៊ុន ត្រូវបានកត់ត្រាជាបំណុលក្នុងការិយបរិច្ឆេទ ដែលវាត្រូវបានអនុម័តដោយភាគទុនិករបស់ក្រុមហ៊ុន។

ភាគលាភក្នុងការិយបរិច្ឆេទដែលបានប្រកាសក្រោយកាលបរិច្ឆេទតារាងតុល្យការ ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ស្តីពីព្រឹត្តការណ៍ក្រោយតារាងតុល្យការ។

## 3. ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យគណនេយ្យសំខាន់ៗ

ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យត្រូវបានវាយតម្លៃជាបន្តបន្ទាប់ ផ្អែកទៅតាមបទពិសោធន៍ក្នុងគ្រាមុន និងកត្តាផ្សេងៗទៀត រួមមានការរំពឹងទុកលើព្រឹត្តិការណ៍នាពេលអនាគត ដែលគេជឿជាក់ថាមានភាពសមហេតុផលទៅតាមកាលៈទេសៈផ្សេងៗ។ ក្រុមហ៊ុនធ្វើការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យ ដោយគិតទៅលើអនាគតកាល។ តាមនិយមន័យលទ្ធផលនៃការប៉ាន់ស្មានគណនេយ្យកម្រស្មើគ្នានឹងលទ្ធផលជាក់ស្តែងណាស់។ ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យដែលមានហានិភ័យជាសារវន្ត បណ្តាលឱ្យមាននិយ័តកម្មធំដុំទៅលើតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុល ក្នុងឆ្នាំបន្ទាប់ត្រូវបានពិភាក្សាដូចខាងក្រោមៈ

### 3.1 សំវិធានធនឥណទានអាក្រក់ និងសង្ស័យ

ក្រុមហ៊ុនអនុវត្តការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន តាមតម្រូវការរបស់ប្រកាសលេខ ធ7-02-186ប្រ.ក. ចុះថ្ងៃទី13 ខែកញ្ញា ឆ្នាំ2002 របស់ធនាគារកណ្តាល។ ធនាគារកណ្តាលតម្រូវឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធ្វើចំណាត់ថ្នាក់ឥណទានរបស់ខ្លួនជាបួនថ្នាក់ ហើយត្រូវប្រាកដថាកម្រិតអប្បបរមានៃសំវិធានធនជាក់លាក់ ត្រូវបានកត់ត្រាអាស្រ័យទៅតាមការធ្វើចំណាត់ថ្នាក់ពាក់ព័ន្ធ។ ក្នុងការធ្វើចំណាត់ថ្នាក់ឥណទាន តម្រូវឱ្យក្រុមហ៊ុនគិតពិចារណាទៅលើប្រវត្តិនៃការសងប្រាក់ និងលក្ខខណ្ឌហិរញ្ញវត្ថុរបស់អ្នកខ្ចីប្រាក់។

ក្រុមហ៊ុនកត់ត្រាសំវិធានធន 100% សម្រាប់ឥណទានបាត់បង់ដែលផុតកាលកំណត់សង 30ថ្ងៃ ឬលើសពី 30ថ្ងៃ។ ចំនួនសំវិធានធនដែលលើសភាគរយកម្រិតតម្រូវដោយធនាគារកណ្តាល ត្រូវបានបង្ហាញជាសំវិធានធនទូទៅ។

### 3.2 ពន្ធ

ពន្ធត្រូវបានគណនាតាមមូលដ្ឋានបំណកស្រាយបច្ចុប្បន្ននៃបទប្បញ្ញត្តិពន្ធដារ ប៉ុន្តែបទប្បញ្ញត្តិទាំងអស់នេះមានការផ្លាស់ប្តូរពីមួយគ្រាទៅមួយគ្រា ហើយការសម្រេចជាចុងក្រោយលើចំនួនពន្ធ នឹងធ្វើឡើងបន្ទាប់ពីអធិការកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ។ នៅពេលដែលលទ្ធផលពន្ធចុងក្រោយខុសគ្នាពីចំនួនដែលបានកត់ត្រាពីដំបូង នោះភាពលម្អៀងនេះនឹងធ្វើឱ្យប៉ះពាល់ដល់ពន្ធលើប្រាក់ចំណេញ និងសំវិធានធនពន្ធពន្យារនៅក្នុងឆ្នាំដែលការកំណត់ពន្ធបានធ្វើឡើង។

### 3.3 រូបិយប័ណ្ណគោល

ក្រុមប្រឹក្សាភិបាលយល់ឃើញថា ប្រាក់រៀលមានផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចជាមូលដ្ឋានលើដំណើរការ ប្រតិបត្តិការព្រឹត្តការណ៍ និងលក្ខខណ្ឌផ្សេងៗ។ ប្រាក់រៀលគឺជារូបិយប័ណ្ណដែលក្រុមហ៊ុនវាស់វែងប្រតិបត្តិការ និងរាយការណ៍ពីលទ្ធផលរបស់ខ្លួន ក៏ដូចជារូបិយប័ណ្ណដែលទទួលបានពីភាគទុនិក និងបង់ភាគលាភទៅឱ្យភាគទុនិករបស់ខ្លួនផងដែរ។ ប្រាក់រៀលគឺជារូបិយប័ណ្ណក្នុងស្រុករបស់ប្រទេសកម្ពុជា។

## 4. សាច់ប្រាក់ក្នុងដៃ

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ការិយាល័យកណ្តាល | 1,141,204 | 282,686 | 45,852 | 11,322 |
| ការិយាល័យសាខា | 7,056,849 | 1,748,043 | 3,835,773 | 947,104 |
| | 8,198,053 | 2,030,729 | 3,881,625 | 958,426 |

## 5. សមតុល្យនៅធនាគារកណ្តាល

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| គណនីចរន្ត (មិនមានការប្រាក់) | 2,974,073 | 736,703 | 31,590,641 | 7,800,158 |
| ប្រាក់តម្កល់ធានាលើដើមទុន (i) | 2,336,820 | 578,851 | 2,336,820 | 576,993 |
| ទុនបម្រុងកាតព្វកិច្ច (ii) | 7,978,400 | 1,976,319 | 113,231 | 27,958 |
| | 13,289,293 | 3,291,873 | 34,040,692 | 8,405,109 |

### (i) ប្រាក់តម្កល់ធានាលើដើមទុន

អនុលោមតាមប្រកាសលេខ ធ7-07-163ប្រ.ក. ចុះថ្ងៃទី13 ខែធ្នូ ឆ្នាំ2007 ស្តីពីការផ្តល់អាជ្ញាប័ណ្ណដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ តម្រូវឱ្យក្រុមហ៊ុនរក្សាប្រាក់តម្កល់ធានាលើដើមទុននៅធនាគារកណ្តាល ចំនួន 10% នៃដើមទុនចុះបញ្ជី។ ប្រាក់តម្កល់នេះនឹងត្រូវបង្វិលជូនក្រុមហ៊ុនវិញ នៅពេលក្រុមហ៊ុនស្ម័គ្រចិត្តបញ្ចប់ប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។ ប្រាក់តម្កល់ធានាលើដើមទុនត្រូវបានតម្កល់ជាប្រាក់រៀល និងទទួលបានការប្រាក់ 3% ក្នុងមួយឆ្នាំ។

### (ii) ទុនបម្រុងកាតព្វកិច្ច

អនុលោមតាមប្រកាសលេខ ធ7-07-163ប្រ.ក. ស្តីពីការផ្តល់អាជ្ញាប័ណ្ណដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីអតិថិជន តម្រូវឱ្យក្រុមហ៊ុនរក្សាទុនបម្រុងកាតព្វកិច្ច ដែលជាតម្រូវការទុនបម្រុងអប្បបរមា ហើយត្រូវបានគណនាតាមអត្រា 8% នៃប្រាក់បញ្ញើរបស់អតិថិជនសរុប។ ទុនបម្រុងកាតព្វកិច្ចពុំមានការប្រាក់ទេ។

## 6. សមតុល្យនៅធនាគារផ្សេងៗ

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| គណនីចរន្ត | 7,308,856 | 1,810,466 | 15,149,529 | 3,740,623 |
| គណនីសន្សំ | 73,207,837 | 18,134,219 | 11,911,967 | 2,941,227 |
| គណនីប្រាក់បញ្ញើមានកាលកំណត់ (*) | 8,881,400 | 2,200,000 | 43,655,880 | 10,779,230 |
| | 89,398,093 | 22,144,685 | 70,717,376 | 17,461,080 |

គណនីចរន្តមិនទទួលបានការប្រាក់ទេ។ អត្រាការប្រាក់ប្រចាំឆ្នាំនៃគណនីប្រាក់បញ្ញើមានកាលកំណត់ និងគណនីសន្សំ ស្ថិតក្នុងចន្លោះពី 0.25% ទៅ 4.75% ក្នុងមួយឆ្នាំ (2015 ៖ 0.25% ទៅ 4.75%)។

(*) គណនីប្រាក់បញ្ញើមានកាលកំណត់ទាំងអស់មានរយៈពេលមួយឆ្នាំ។ ប្រាក់បញ្ញើរទាំងនេះត្រូវបានដាក់បញ្ចាំដើម្បីទទួលបានប្រាក់កម្ចីពីធនាគារក្នុងស្រុក (កំណត់សម្គាល់14)។

## 7. ឥណទានអតិថិជន

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ឥណទានក្រុមសាមគ្គីៈ | | | | |
| ឥណទានមានកាលកំណត់ | 59,506,886 | 14,740,373 | 53,251,093 | 13,148,418 |
| ឥណទានបញ្ចប់វគ្គ | 154,912,193 | 38,373,097 | 190,061,900 | 46,928,864 |
| ឥណទានឯកត្តជនៈ | | | | |
| ឥណទានមានកាលកំណត់ | 494,822,931 | 122,571,942 | 360,727,863 | 89,068,608 |
| ឥណទានបញ្ចប់វគ្គ | 163,682,628 | 40,545,610 | 149,478,071 | 36,908,166 |
| ឥណទានបុគ្គលិក | 13,353,480 | 3,307,774 | 9,318,156 | 2,300,779 |
| | 886,278,118 | 219,538,796 | 762,837,083 | 188,354,835 |
| សំវិធានធនឥណទានអាក្រក់ និងសង្ស័យ | | | | |
| សំវិធានធនជាក់លាក់ | (3,569,416) | (884,175) | (658,472) | (162,586) |
| សំវិធានធនទូទៅ | (8,537,617) | (2,114,843) | (1,189,681) | (293,748) |
| | (12,107,033) | (2,999,018) | (1,848,153) | (456,334) |
| ឥណទានអតិថិជនសុទ្ធ | 874,171,085 | 216,539,778 | 760,988,930 | 187,898,501 |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016**

## 7. ឥណទានអតិថិជន (ត)

បម្រែបម្រួលសំវិធានធនឥណទានអតិថិជនអាក្រក់ និងសង្ស័យ មានដូចខាងក្រោម៖

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| សមតុល្យដើមឆ្នាំ | 1,848,153 | 461,346 | 463,853 | 113,829 |
| សំវិធានធនក្នុងឆ្នាំ | 14,989,712 | 3,713,082 | 1,952,391 | 482,072 |
| ជម្រះពីបញ្ជីក្នុងឆ្នាំ | (4,634,209) | (1,147,934) | (554,820) | (136,993) |
| ខាតពីការប្តូររូបិយប័ណ្ណ | (96,623) | (23,934) | (13,271) | (3,277) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (3,542) | - | 703 |
| សមតុល្យចុងឆ្នាំ | 12,107,033 | 2,999,018 | 1,848,153 | 456,334 |

ឥណទានអតិថិជនត្រូវបានវិភាគដូចខាងក្រោម៖

### (ក) វិភាគតាមវិស័យសេដ្ឋកិច្ច

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| កសិកម្ម | 459,485,171 | 113,818,472 | 365,376,576 | 90,216,439 |
| ផ្ទះ/គ្រួសារ | 155,376,923 | 38,488,215 | 171,373,286 | 42,314,392 |
| ជំនួញ និងពាណិជ្ជកម្ម | 151,625,171 | 37,558,873 | 126,990,749 | 31,355,740 |
| សេវាកម្ម | 89,540,568 | 22,179,977 | 74,085,515 | 18,292,720 |
| សំណង់ | 15,683,005 | 3,884,817 | 12,468,379 | 3,078,612 |
| ដឹកជញ្ជូន | 2,864,530 | 709,569 | 1,852,388 | 457,380 |
| វិស័យផ្សេងៗ | 11,702,750 | 2,898,873 | 10,690,190 | 2,639,552 |
| | 886,278,118 | 219,538,796 | 762,837,083 | 188,354,835 |

### (ខ) វិភាគតាមស្ថានភាពនិវេសនដ្ឋាន

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| និវេសនដ្ឋាន | 886,278,118 | 219,538,796 | 762,837,083 | 188,354,835 |

## 7. ឥណទានអតិថិជន (ត)

### (គ) វិភាគតាមទំនាក់ទំនង

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ឥណទានអតិថិជន | 872,924,638 | 216,231,022 | 753,518,927 | 186,054,056 |
| ឥណទានបុគ្គលិក | 13,353,480 | 3,307,774 | 9,318,156 | 2,300,779 |
| | 886,278,118 | 219,538,796 | 762,837,083 | 188,354,835 |

### (ឃ) វិភាគតាមចំណាត់ថ្នាក់ឥណទាន

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ឥណទានស្តង់ដារ | | | | |
| មានការធានា | 663,911,466 | 164,456,643 | 518,689,562 | 128,071,497 |
| មិនមានការធានា | 210,259,620 | 52,083,136 | 242,299,371 | 59,827,004 |
| ឥណទានក្រោមស្តង់ដារ | | | | |
| មានការធានា | 6,060,797 | 1,501,312 | 544,623 | 134,475 |
| មិនមានការធានា | 1,454,879 | 360,386 | 393,046 | 97,048 |
| ឥណទានសង្ស័យ | | | | |
| មានការធានា | 1,566,050 | 387,924 | 229,031 | 56,551 |
| មិនមានការធានា | 967,534 | 239,667 | 264,934 | 65,416 |
| ឥណទានបាត់បង់ | | | | |
| មានការធានា | 320,726 | 79,447 | 60,874 | 15,031 |
| មិនមានការធានា | 1,737,046 | 430,281 | 355,642 | 87,813 |
| | 886,278,118 | 219,538,796 | 762,837,083 | 188,354,835 |

### (ង) វិភាគតាមអត្រាការប្រាក់ (ប្រចាំខែ)

អត្រាការប្រាក់ប្រចាំខែ មានដូចខាងក្រោម ៖

| | គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2016 | គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2015 |
|---|---|---|
| ឥណទានជាប្រាក់រៀល | 2.00% - 3.50% | 2.50% - 3.50% |
| ឥណទានជាប្រាក់ដុល្លារអាមេរិក | 1.30% - 3.50% | 1.60% - 3.50% |
| ឥណទានជាប្រាក់បាតថៃ | 2.00% - 3.50% | 2.45% - 3.50% |

## 8. ទ្រព្យសកម្មផ្សេងៗ

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| បង្គរការប្រាក់ត្រូវទទួល-សុទ្ធ | 12,833,843 | 3,179,054 | 12,576,598 | 3,105,333 |
| ចំណាយបង់មុន | 4,063,292 | 1,006,513 | 6,787,820 | 1,676,005 |
| ចំណាយរំលស់ប្រាក់កម្ចី | 2,978,228 | 737,733 | 2,727,547 | 673,468 |
| ផ្សេងៗ | 688,853 | 170,635 | 1,274,242 | 314,628 |
| | 20,564,216 | 5,093,935 | 23,366,207 | 5,769,434 |

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

### 9. ទ្រព្យសម្បត្តិ និងបរិក្ខារ

| | សង្ហារិម និងបរិក្ខារ ការិយាល័យ ពាន់រៀល | យានយន្ត ពាន់រៀល | បរិក្ខារកុំព្យូទ័រ ពាន់រៀល | ការកែលម្អ ទ្រព្យជួល ពាន់រៀល | ការងារកំពុង ដំណើរការ ពាន់រៀល | សរុប ពាន់រៀល |
|---|---|---|---|---|---|---|
| **នៅថ្ងៃទី01 ខែមករា ឆ្នាំ2015** | | | | | | |
| ថ្លៃដើម | 994,354 | 7,445,143 | 2,458,718 | 625,326 | - | 11,523,541 |
| រំលស់បង្គរ | (483,118) | (4,166,685) | (1,872,730) | (52,127) | - | (6,574,660) |
| **តម្លៃចុះបញ្ជីសុទ្ធ** | 511,236 | 3,278,458 | 585,988 | 573,199 | - | 4,948,881 |
| **ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2015** | | | | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | 511,236 | 3,278,458 | 585,988 | 573,199 | - | 4,948,881 |
| ទិញបន្ថែម | 440,927 | 2,323,557 | 799,215 | 55,432 | - | 3,619,131 |
| លក់ចេញ | - | (5,653) | (166) | (3,269) | - | (9,088) |
| រំលស់ | (262,911) | (1,463,733) | (429,192) | (67,510) | - | (2,223,346) |
| **តម្លៃចុះបញ្ជីសុទ្ធចុងគ្រា** | 689,252 | 4,132,629 | 955,845 | 557,852 | - | 6,335,578 |
| **នៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2015** | | | | | | |
| ថ្លៃដើម | 1,429,120 | 9,673,334 | 3,011,890 | 676,955 | - | 14,791,299 |
| រំលស់បង្គរ | (739,868) | (5,540,705) | (2,056,045) | (119,103) | - | (8,455,721) |
| **តម្លៃចុះបញ្ជីសុទ្ធ** | 689,252 | 4,132,629 | 955,845 | 557,852 | - | 6,335,578 |
| **គិតជាដុល្លារអាមេរិក** | 170,186 | 1,020,402 | 236,011 | 137,741 | - | 1,564,340 |
| **នៅថ្ងៃទី01 ខែមករា ឆ្នាំ2016** | | | | | | |
| ថ្លៃដើម | 1,429,120 | 9,673,334 | 3,011,890 | 676,955 | - | 14,791,299 |
| រំលស់បង្គរ | (739,868) | (5,540,705) | (2,056,045) | (119,103) | - | (8,455,721) |
| **តម្លៃចុះបញ្ជីសុទ្ធ** | 689,252 | 4,132,629 | 955,845 | 557,852 | - | 6,335,578 |
| **ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016** | | | | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | 689,252 | 4,132,629 | 955,845 | 557,852 | - | 6,335,578 |
| ទិញបន្ថែម | 945,843 | 2,226,204 | 1,038,874 | 353,377 | 1,990,463 | 6,554,761 |
| លក់ចេញ | (42) | (15,994) | (4,478) | - | - | (20,514) |
| រំលស់ | (514,288) | (2,214,219) | (739,271) | (116,381) | - | (3,584,159) |
| **តម្លៃចុះបញ្ជីសុទ្ធចុងគ្រា** | 1,120,765 | 4,128,620 | 1,250,970 | 794,848 | 1,990,463 | 9,285,666 |
| **គិតជាដុល្លារអាមេរិក** | 277,623 | 1,022,695 | 309,876 | 196,891 | 493,055 | 2,300,140 |

ការងារកំពុងដំណើរការគឺជាឧបករណ៍សម្រាប់ប្រព័ន្ធកម្មវិធីកុំព្យូទ័រធនាគារថ្មី (T-24) ដែលកំពុងដំឡើង ប៉ុន្តែមិនទាន់រួចរាល់សម្រាប់ប្រើប្រាស់នៅឡើយទេ។

## 10. ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី រួមមានថ្លៃដើមកម្មវិធីកុំព្យូទ័រ និងកម្រៃអាជ្ញាប័ណ្ណ ដែលមានសេចក្ដីលម្អិតដូចខាងក្រោម ៖

| | 2016 | | | 2015 |
|---|---|---|---|---|
| | **ការងារកំពុងដំណើរការ ពាន់រៀល** | **កម្មវិធីកុំព្យូទ័រ និងកម្រៃអាជ្ញាប័ណ្ណ ពាន់រៀល** | **សរុប ពាន់រៀល** | **សរុប ពាន់រៀល** |
| **នាដើមឆ្នាំ** | | | | |
| ថ្លៃដើម | - | 282,014 | 282,014 | 271,732 |
| រំលស់បង្គរ | - | (207,972) | (207,972) | (188,663) |
| **តម្លៃចុះបញ្ជីសុទ្ធ** | - | 74,042 | 74,042 | 83,069 |
| **ដំណាច់ឆ្នាំ** | | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | - | 74,042 | 74,042 | 83,069 |
| ទិញបន្ថែម | 2,298,578 | - | 2,298,578 | 10,283 |
| រំលស់ | - | (20,699) | (20,699) | ( 19,309) |
| **តម្លៃចុះបញ្ជីសុទ្ធចុងគ្រា** | 2,298,578 | 53,343 | 2,351,921 | 74,043 |
| **ដំណាច់ឆ្នាំ** | | | | |
| ថ្លៃដើម | 2,298,578 | 282,014 | 2,580,592 | 282,014 |
| រំលស់បង្គរ | - | (228,671) | (228,671) | (207,972) |
| **តម្លៃចុះបញ្ជីសុទ្ធ** | 2,298,578 | 53,343 | 2,351,921 | 74,042 |
| **គិតជាដុល្លារអាមេរិក** | 569,377 | 13,215 | 582,592 | 18,282 |

ការងារកំពុងដំណើរការគឺជាប្រព័ន្ធកម្មវិធីកុំព្យូទ័រធនាគារថ្មី (T-24) ដែលកំពុងដំឡើង ប៉ុន្តែមិនទាន់រួចរាល់សម្រាប់ប្រើប្រាស់នៅឡើយទេ។

## 11. ពន្ធ

### (ក) ពន្ធពន្យារទ្រព្យសកម្ម

ការវិភាគពន្ធពន្យារទ្រព្យសកម្ម និងបំណុលពន្ធពន្យារ មានដូចខាងក្រោម៖

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ពន្ធពន្យារទ្រព្យសកម្ម | 3,444,234 | 853,167 | 1,322,570 | 326,561 |
| បំណុលពន្ធពន្យារ | - | - | (52,370) | (12,931) |
| ពន្ធពន្យារទ្រព្យសកម្ម-សុទ្ធ | 3,444,234 | 853,167 | 1,270,200 | 313,630 |

បម្រែបម្រួលពន្ធពន្យារទ្រព្យសកម្មសុទ្ធ មានដូចខាងក្រោម ៖

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| សមតុល្យដើមឆ្នាំ | 1,270,200 | 313,630 | 719,288 | 176,512 |
| កត់ត្រាក្នុងខ្ទង់ឥណទានក្នុងរបាយការណ៍លទ្ធផល | 2,174,034 | 538,527 | 550,912 | 136,028 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | 1,010 | - | 1,090 |
| សមតុល្យចុងឆ្នាំ | 3,444,234 | 853,167 | 1,270,200 | 313,630 |

## 11. ពន្ធ (ត)

### (គ) ពន្ធពន្យារទ្រព្យសកម្ម (ត)

បម្រែបម្រួលពន្ធពន្យារទ្រព្យសកម្ម/(បំណុល)សុទ្ធ នៅក្នុងការិយបរិច្ឆេទមានដូចខាងក្រោម ៖

| | សំវិធានធនទូទៅលើឥណទានបាត់បង់<br>ពាន់រៀល | ប្រាក់រង្វាន់ និងការសម្រាកប្រចាំឆ្នាំដែលមិនបានប្រើប្រាស់<br>ពាន់រៀល | ខាតពីការប្តូររូបិយប័ណ្ណដែលមិនទាន់ទទួលស្គាល់<br>ពាន់រៀល | រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបី<br>ពាន់រៀល | បន្ទុកផ្សេងៗ<br>ពាន់រៀល | សរុប<br>ពាន់រៀល |
|---|---|---|---|---|---|---|
| នៅថ្ងៃទី01 ខែមករា ឆ្នាំ2015 | 50,983 | 581,259 | 119,735 | (32,689) | - | 719,288 |
| កត់ត្រាក្នុងខ្ទង់ឥណទាន/(ជាបន្ទុក)ក្នុងរបាយការណ៍លទ្ធផល | 186,951 | 200,741 | 80,591 | (19,681) | 102,310 | 550,912 |
| នៅត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2015 | 237,934 | 782,000 | 200,326 | (52,370) | 102,310 | 1,270,200 |
| គិតជាដុល្លារអាមេរិក | 58,749 | 193,086 | 49,463 | (12,931) | 25,263 | 313,630 |
| | | | | | | |
| គិតត្រឹមថ្ងៃទី01 ខែមករា ឆ្នាំ2016 | 237,934 | 782,000 | 200,326 | (52,370) | 102,310 | 1,270,200 |
| កត់ត្រាក្នុងខ្ទង់ឥណទានក្នុងរបាយការណ៍លទ្ធផល | 1,619,903 | 289,063 | 73,241 | 132,657 | 59,170 | 2,174,034 |
| គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2016 | 1,857,837 | 1,071,063 | 273,567 | 80,287 | 161,480 | 3,444,234 |
| គិតជាដុល្លារអាមេរិក | 460,202 | 265,312 | 67,765 | 19,888 | 40,000 | 853,167 |

## 11. ពន្ធ (ត)

### (ខ) ចំណាយពន្ធលើប្រាក់ចំណេញ

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ពន្ធលើប្រាក់ចំណេញក្នុងឆ្នាំ | 16,110,117 | 3,990,616 | 12,886,332 | 3,181,810 |
| ពន្ធពន្យារទ្រព្យសកម្ម | (2,174,034) | (538,527) | (550,912) | (136,028) |
| ចំណាយពន្ធលើប្រាក់ចំណេញ | 13,936,083 | 3,452,089 | 12,335,420 | 3,045,782 |

(i) បំណុលពន្ធលើប្រាក់ចំណេញ

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| សមតុល្យដើមគ្រា | 11,308,037 | 2,792,108 | 6,677,587 | 1,638,672 |
| ចំណាយពន្ធលើប្រាក់ចំណេញក្នុងឆ្នាំ | 15,527,520 | 3,846,302 | 12,886,332 | 3,181,810 |
| ពន្ធលើប្រាក់ចំណេញបានបង់ | (12,889,230) | (3,192,774) | (8,255,882) | (2,038,489) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | 8,990 | - | 10,115 |
| សមតុល្យចុងគ្រា | 13,946,327 | 3,454,626 | 11,308,037 | 2,792,108 |

(ii) ការផ្ទៀងផ្ទាត់បន្ទុកពន្ធលើប្រាក់ចំណេញ ដែលត្រូវបានគណនាតាមអត្រាពន្ធកំណត់តាមច្បាប់ ធៀបនឹងបន្ទុកពន្ធលើប្រាក់ចំណេញ ដែលបានបង្ហាញលើរបាយការណ៍លទ្ធផល មានដូចខាងក្រោម ៖

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ | 68,931,021 | 17,074,813 | 61,144,991 | 15,097,528 |
| ពន្ធគណនាតាមអត្រា 20% | 13,786,204 | 3,414,963 | 12,228,998 | 3,019,506 |
| ចំណាយដែលមិនអាចកាត់កងតាមច្បាប់ពន្ធ | 149,879 | 37,126 | 106,422 | 26,276 |
| | 13,936,083 | 3,452,089 | 12,335,420 | 3,045,782 |

អនុលោមតាមច្បាប់សារពើពន្ធកម្ពុជា ក្រុមហ៊ុនមានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណេញ តាមអត្រាមួយណាដែលខ្ពស់ជាងគេ រវាងពន្ធលើប្រាក់ចំណេញតាមអត្រា20%នៃប្រាក់ចំណេញជាប់ពន្ធ ឬពន្ធអប្បបរមា 1% នៃផលរបរ។

## 12. ប្រាក់បញ្ញើ

### (ក) ប្រាក់បញ្ញើរបស់គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ប្រាក់បញ្ញើសន្សំ | 52 | 14 | - | - |
| ប្រាក់បញ្ញើមានកាលកំណត់ | 24,222,000 | 6,000,000 | - | - |
| | 24,222,052 | 6,000,014 | - | - |

ប្រាក់បញ្ញើរបស់គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ មានអត្រាការប្រាក់ប្រចាំឆ្នាំ អាស្រ័យទៅតាមលក្ខខណ្ឌ និងប្រភេទរូបិយប័ណ្ណដូចខាងក្រោម។ ប្រាក់បញ្ញើរបស់គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ ភាគច្រើនមានកាលកំណត់រយៈពេលមួយឆ្នាំ។

| | |
|---|---|
| ប្រាក់បញ្ញើសន្សំ - អត្រាការប្រាក់ប្រចាំឆ្នាំ | 1% |
| ប្រាក់បញ្ញើមានកាលកំណត់ - អត្រាការប្រាក់ប្រចាំឆ្នាំ | 4.75% - 8.25% |

### (ខ) ប្រាក់បញ្ញើអតិថិជន

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ប្រាក់បញ្ញើសន្សំ | 7,143,410 | 1,769,485 | 548,004 | 135,310 |
| ប្រាក់បញ្ញើមានកាលកំណត់ | 46,757,358 | 11,582,204 | 566,632 | 139,909 |
| | 53,900,768 | 13,351,689 | 1,114,636 | 275,219 |

ប្រាក់បញ្ញើអតិថិជនមានអត្រាការប្រាក់ប្រចាំឆ្នាំ អាស្រ័យទៅតាមលក្ខខណ្ឌ និងប្រភេទរូបិយប័ណ្ណដូចខាងក្រោម។ ប្រាក់បញ្ញើអតិថិជន ភាគច្រើនមានកាលកំណត់រយៈពេលមួយឆ្នាំ លើកលែងតែទឹកប្រាក់ចំនួន 5,820លានរៀល ដែលមានកាលកំណត់លើសពីមួយឆ្នាំ។

| | 2016 | 2015 |
|---|---|---|
| ប្រាក់បញ្ញើសន្សំ - អត្រាការប្រាក់ប្រចាំឆ្នាំ | 1% - 4% | 1% - 3% |
| ប្រាក់បញ្ញើមានកាលកំណត់ - អត្រាការប្រាក់ប្រចាំឆ្នាំ | 3.5% - 11% | 3.5% - 10.5% |

## 13. ឥណទានវិបារូបន៍

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ឥណទានវិបារូបន៍ | - | - | 3,980,411 | 982,818 |
| | - | - | 3,980,411 | 982,818 |

ឥណទានវិបារូបន៍មិនមានការធានា និងមានរយៈពេលមួយឆ្នាំ ហើយមានអត្រាការប្រាក់ពី 9.3% ទៅ 10% ក្នុងមួយឆ្នាំ។

ក្រុមហ៊ុននៅមានឥណទានវិបារូបន៍ដែលមិនទាន់បានប្រើប្រាស់ ដូចខាងក្រោម៖

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| សមតុល្យដែលអនុម័ត | 20,255,500 | 5,017,463 | 20,075,000 | 4,956,790 |
| សមតុល្យបានប្រើប្រាស់ | - | - | (3,980,411) | (982,818) |
| សមតុល្យមិនបានប្រើប្រាស់ | 20,255,500 | 5,017,463 | 16,094,589 | 3,973,972 |

## 14. ប្រាក់កម្ចី

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ប្រាក់កម្ចីពីធនាគារក្នុងស្រុក | 60,574,525 | 15,004,837 | 91,350,000 | 22,555,555 |
| ប្រាក់កម្ចីពីធនាគារក្រៅស្រុក (*) | 647,713,888 | 160,444,361 | 625,795,414 | 154,517,387 |
| | 708,288,413 | 175,449,198 | 717,145,414 | 177,072,942 |

(*) ប្រាក់កម្ចីនេះរួមបញ្ចូលអនុបំណុលដែលមានចំនួនទឹកប្រាក់ប្រមាណជា 48ពាន់លានរៀល (គិតជាប្រាក់ដុល្លារអាមេរិកចំនួន 12លានដុល្លារអាមេរិក) ដែលបានអនុម័តដោយធនាគារកណ្តាល។

នៅក្នុងប្រាក់កម្ចីនេះ មានប្រាក់កម្ចីចំនួន 376ពាន់លានរៀល ដែលកាលកំណត់លើសពីមួយឆ្នាំ។

អត្រាការប្រាក់ប្រចាំឆ្នាំមានដូចខាងក្រោម៖

| | 2016 | 2015 |
|---|---|---|
| កម្ចីជាប្រាក់រៀល | 6.00% - 12.35% | 9.00% - 12.35% |
| កម្ចីជាប្រាក់ដុល្លារអាមេរិក | 2.55% - 10.50% | 2.55% - 10.50% |
| កម្ចីជាប្រាក់បាតថៃ | 9.00% - 10.50% | 8.50% - 10.85% |

## 15. បំណុលផ្សេងៗ

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| បង្គរការប្រាក់ត្រូវបង់ | 10,993,736 | 2,723,244 | 8,880,172 | 2,192,635 |
| បង្គរប្រាក់រង្វាន់ និងប្រាក់លើកទឹកចិត្តបុគ្គលិក | 9,807,661 | 2,429,443 | 9,119,629 | 2,251,760 |
| ពន្ធកាត់ទុកត្រូវបង់ | 942,338 | 233,425 | 942,195 | 232,641 |
| បង្គរចំណាយផ្សេងៗ | 561,946 | 139,199 | 603,386 | 148,984 |
| បំណុលផ្សេងៗ | 2,185,287 | 541,314 | 1,840,253 | 454,383 |
| | 24,490,968 | 6,066,625 | 21,385,635 | 5,280,403 |

នៅក្នុងបំណុលផ្សេងៗ មានចំនួន 512លានរៀល ត្រូវបានរំពឹងថានឹងទូទាត់លើសពីមួយឆ្នាំ។

## 16. ដើមទុន

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| LOLC Micro Investments Ltd | 14,021,000 | 3,473,124 | 14,021,000 | 3,461,975 |
| DWM Funds S.C.A.-SICAV SIF | 8,639,200 | 2,140,005 | 8,639,200 | 2,133,136 |
| TPC-ESOP Co., Ltd | 708,000 | 175,377 | 708,000 | 174,815 |
| | 23,368,200 | 5,788,506 | 23,368,200 | 5,769,926 |

ម្ចាស់កម្មសិទ្ធិ និងចំនួនភាគហ៊ុន ត្រូវបានបង្ហាញដូចខាងក្រោម ៖

| | 2016 | | 2015 | |
|---|---|---|---|---|
| | ម្ចាស់កម្មសិទ្ធិ | ចំនួនភាគហ៊ុន | ម្ចាស់កម្មសិទ្ធិ | ចំនួនភាគហ៊ុន |
| LOLC Micro Investments Ltd | 60.00% | 140,210 | 60.00% | 140,210 |
| DWM Funds S.C.A.-SICAV SIF | 36.97% | 86,392 | 36.97% | 86,392 |
| TPC-ESOP Co., Ltd (*) | 3.03% | 7,080 | 3.03% | 7,080 |
| | 100.00% | 233,682 | 100.00% | 233,682 |

គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2016 ក្រុមហ៊ុនមានភាគហ៊ុនធម្មតាសរុបចំនួន 233,682 ភាគហ៊ុន ដែលមានតម្លៃចារិក 100,000រៀលក្នុងមួយភាគហ៊ុន (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2015 ៖ 233,682 ភាគហ៊ុន ដែលមានតម្លៃចារិក 100,000រៀល ក្នុងមួយភាគហ៊ុន)។ រាល់ភាគហ៊ុនដែលបានអនុម័ត ត្រូវបានចេញផ្សាយ និងបានទូទាត់គ្រប់ចំនួន។

16. ដើមទុន (ត)

(*) TPC-ESOP ត្រូវបានបង្កើតឡើងដោយអនុញ្ញាតឱ្យបុគ្គលិកពេញសិទ្ធិ មានឱកាសទិញភាគហ៊ុនរបស់ក្រុមហ៊ុន។ ESOP ត្រូវបានចាត់ទុកជាអត្ថប្រយោជន៍បុគ្គលិក ដែលអាចឱ្យបុគ្គលិកអាចចូលរួមចំណែកអភិវឌ្ឍក្រុមហ៊ុនក្នុងរយៈពេលវែង។

## 17. ចំណូលការប្រាក់

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ចំណូលការប្រាក់ពី ៖ | | | | |
| ឥណទានអតិថិជន | 224,265,482 | 55,552,510 | 166,150,473 | 41,024,808 |
| ប្រាក់បញ្ញើនៅធនាគារកណ្តាល និងធនាគារផ្សេងៗ | 1,468,084 | 363,657 | 2,266,281 | 559,576 |
| | 225,733,566 | 55,916,167 | 168,416,754 | 41,584,384 |

## 18. ចំណាយការប្រាក់

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ប្រាក់កម្ចីក្នុងស្រុក | 7,024,025 | 1,739,912 | 8,933,746 | 2,205,863 |
| ប្រាក់កម្ចីក្រៅស្រុក | 61,338,795 | 15,194,153 | 40,153,649 | 9,914,481 |
| ប្រាក់បញ្ញើរបស់គ្រឹះស្ថានហិរញ្ញវត្ថុ និងប្រាក់បញ្ញើអតិថិជន | 2,899,175 | 718,151 | 5,527 | 1,365 |
| | 71,261,995 | 17,652,216 | 49,092,922 | 12,121,709 |

## 19. ចំណូលផ្សេងៗ

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ចំណូល និងកម្រៃជើងសារពីឥណទាន | 9,198,331 | 2,278,507 | 4,925,356 | 1,216,137 |
| ការប្រមូលឥណទានដែលបានជម្រះចេញពីបញ្ជីមកវិញ | 333,467 | 82,603 | 281,251 | 69,445 |
| ចំណូលបានមកពីការផាកពិន័យ | 141,705 | 35,102 | 93,622 | 23,117 |
| ចំណេញពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | 50,391 | 12,482 | 28,427 | 7,019 |
| ចំណូលផ្សេងៗ | 221,284 | 54,813 | 114,977 | 28,389 |
| | 9,945,178 | 2,463,507 | 5,443,633 | 1,344,107 |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2016**

## 20. ចំណាយកម្រៃជើងសារ

ចំណាយកម្រៃជើងសារគឺជាចំណាយបង់ទៅឱ្យអ្នកសម្របសម្រួលប្រមូលប្រាក់ពីក្រុមឥណទាន និងការិយាល័យឥណទានកម្ពុជា ចំពោះការស៊ើបសួរព័ត៌មានរបស់អតិថិជន។

## 21. ចំណាយបុគ្គលិក

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ប្រាក់បៀវត្សរ៍ និងប្រាក់ឈ្នួល | 43,873,867 | 10,867,938 | 33,661,610 | 8,311,509 |
| អត្ថប្រយោជន៍រយៈពេលខ្លីផ្សេងៗ | 4,685,837 | 1,160,723 | 3,707,989 | 915,552 |
| | 48,559,704 | 12,028,661 | 37,369,599 | 9,227,061 |

## 22. ចំណាយទូទៅ និងចំណាយរដ្ឋបាល

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ចំណាយជួល | 5,429,083 | 1,344,831 | 3,039,527 | 750,500 |
| ចំណាយសេវាធនាគារ និងកម្រៃសេវាផ្សេងៗ | 3,769,906 | 933,838 | 3,135,983 | 774,317 |
| ចំណាយធ្វើដំណើរ | 3,504,236 | 868,030 | 2,585,400 | 638,370 |
| ចំណាយទីផ្សារ | 1,830,546 | 453,442 | 1,566,015 | 386,670 |
| ចំណាយសម្ភារ និងបរិក្ខារការិយាល័យ | 1,706,080 | 422,611 | 1,700,527 | 419,883 |
| កម្រៃអាជ្ញាប័ណ្ណ | 1,108,418 | 274,565 | 298,681 | 73,748 |
| ចំណាយទឹកភ្លើង | 1,089,260 | 269,819 | 838,452 | 207,025 |
| ចំណាយទំនាក់ទំនង | 940,232 | 232,904 | 767,329 | 189,464 |
| ចំណាយសន្តិសុខ | 899,957 | 222,927 | 720,416 | 177,880 |
| ចំណាយសេវាវិជ្ជាជីវៈ | 829,278 | 205,419 | 778,994 | 192,344 |
| ចំណាយបោះពុម្ព និងថតចម្លង | 420,717 | 104,215 | 341,707 | 84,375 |
| ចំណាយក្រុមប្រឹក្សាភិបាល | 440,010 | 108,994 | 356,628 | 88,056 |
| ចំណាយផ្សេងៗ | 5,490,830 | 1,360,127 | 2,714,265 | 670,189 |
| | 27,458,553 | 6,801,722 | 18,843,924 | 4,652,821 |

## 23. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ឥណទានវិបារូបន៍ | - | - | (3,980,411) | (982,818) |
| សាច់ប្រាក់ក្នុងដៃ | 8,198,053 | 2,030,729 | 3,881,625 | 958,426 |
| សមតុល្យនៅធនាគារកណ្តាល ដែលមាន រយៈពេលបីខែឬតិចជាងបីខែ | 2,974,073 | 736,703 | 29,140,590 | 7,195,207 |
| សមតុល្យនៅធនាគារផ្សេងៗ ដែលមាន រយៈពេលបីខែឬតិចជាងបីខែ | 89,398,093 | 22,144,685 | 31,965,626 | 7,892,747 |
| | 100,570,219 | 24,912,117 | 61,007,430 | 15,063,562 |

## 24. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ

| ទំនាក់ទំនង | ភាគីពាក់ព័ន្ធ |
|---|---|
| ក្រុមហ៊ុនមេធំជាងគេ | Lanka ORIX Leasing Company PLC |
| ក្រុមហ៊ុនមេផ្ទាល់ | LOLC Micro Investments Ltd |
| បុគ្គលិកគណៈគ្រប់គ្រងសំខាន់ | ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនទាំងអស់ ដែលធ្វើការសម្រេចចិត្តសំខាន់ៗពាក់ព័ន្ធនឹងទិសដៅយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន និងគណៈគ្រប់គ្រងជាន់ខ្ពស់ (រាប់ទាំងសមាជិកគ្រួសារជិតដិតរបស់ពួកគេ)។ |

ប្រតិបត្តិការភាគីពាក់ព័ន្ធ និងសមតុល្យដែលនៅមិនទាន់ទូទាត់ សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016 មានដូចខាងក្រោម ៖

### (ក) កម្រៃក្រុមប្រឹក្សាភិបាល

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| កម្រៃក្រុមប្រឹក្សាភិបាល | 440,010 | 108,994 | 356,628 | 88,056 |

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

### 24. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ (ត)

### (ខ) ការទូទាត់ជូនគណៈគ្រប់គ្រងសំខាន់ៗ

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| បង្គរប្រាក់បៀវត្សរ៍ និងអត្ថប្រយោជន៍ រយៈពេលខ្លីត្រូវបង់ | 766,103 | 189,770 | 616,473 | 152,215 |

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ចំណាយប្រាក់បៀវត្សរ៍ និងអត្ថប្រយោជន៍ រយៈពេលខ្លី | 2,026,568 | 501,999 | 1,184,804 | 292,544 |

### (គ) ឥណទានផ្តល់ឱ្យគណៈគ្រប់គ្រងសំខាន់ៗ

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ឥណទានមិនទាន់ទូទាត់ | - | - | 317,008 | 78,274 |
| បង្គរការប្រាក់ត្រូវទទួល | - | - | 423 | 104 |
| | - | - | 317,431 | 78,378 |

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ចំណូលការប្រាក់ | - | - | 7,422 | 1,821 |

## 24. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ (ត)

### (ឃ) ឥណទានផ្តល់ឱ្យភាគទុនិក (តំណាងរបស់ TPC-ESOP)

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ឥណទានមិនទាន់ទូទាត់ | 101,281 | 25,088 | 96,041 | 23,714 |
| បង្គរការប្រាក់ត្រូវទទួល | 135 | 33 | 128 | 32 |
| | 101,416 | 25,121 | 96,169 | 23,746 |

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ចំណូលការប្រាក់ | 11,422 | 2,829 | 5,728 | 1,414 |

### (ង) ប្រាក់បញ្ញើរបស់ភាគីពាក់ព័ន្ធ

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| **ភាគទុនិក ៖** | | | | |
| ប្រាក់បញ្ញើមិនទាន់ទូទាត់ | 169,259 | 41,927 | 158,168 | 39,054 |
| បង្គរការប្រាក់ត្រូវបង់ | 1,695 | 420 | 1,607 | 397 |
| | 170,954 | 42,347 | 159,775 | 39,451 |
| **ក្រុមប្រឹក្សាភិបាល ៖** | | | | |
| ប្រាក់បញ្ញើមិនទាន់ទូទាត់ | 230,750 | 57,159 | 26,732 | 6,600 |
| បង្គរការប្រាក់ត្រូវបង់ | 7,401 | 1,833 | 221 | 55 |
| | 238,151 | 58,992 | 26,953 | 6,655 |
| **គណៈគ្រប់គ្រងសំខាន់ៗ ៖** | | | | |
| ប្រាក់បញ្ញើមិនទាន់ទូទាត់ | 421,675 | 104,453 | 46,087 | 11,379 |
| បង្គរការប្រាក់ត្រូវបង់ | 24,784 | 6,139 | 136 | 34 |
| | 446,459 | 110,592 | 46,223 | 11,413 |

## 24. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ (ត)

### (ខ) ប្រាក់បញ្ញើរបស់ភាគីពាក់ព័ន្ធ (ត)

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| **ចំណាយការប្រាក់លើប្រាក់បញ្ញើរបស់ភាគីពាក់ព័ន្ធៈ** | | | | |
| ភាគទុនិក | 935 | 232 | 1,868 | 461 |
| ក្រុមប្រឹក្សាភិបាល | 8,188 | 2,028 | 257 | 63 |
| គណៈគ្រប់គ្រងសំខាន់ៗ | 30,852 | 7,642 | 744 | 184 |
| | 39,975 | 9,902 | 2,869 | 708 |

### (ច) ប្រាក់កម្ចីពីភាគទុនិក

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ប្រាក់កម្ចីមិនទាន់ទូទាត់ | 7,357,952 | 1,822,629 | 11,496,800 | 2,838,716 |
| បង្គរការប្រាក់ត្រូវបង់ | 115,447 | 28,597 | 321,751 | 79,445 |
| | 7,473,399 | 1,851,226 | 11,818,551 | 2,918,161 |

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ចំណាយការប្រាក់ | 735,001 | 182,066 | 374,129 | 92,377 |

## 25. កិច្ចសន្យាផ្សេងៗ

### (ក) កិច្ចសន្យាភតិសន្យាប្រតិបត្តិ

ភតិសន្យាប្រតិបត្តិទាំងនេះភាគច្រើនពាក់ព័ន្ធទៅនឹងការជួលការិយាល័យ ដែលអាចជួលបន្តជាថ្មីទៀតបាន អាស្រ័យលើកិច្ចព្រមព្រៀងរវាងក្រុមហ៊ុន និងម្ចាស់ទីតាំង។ ករណីដែលក្រុមហ៊ុនជាអ្នកជួល ការចំណាយលើថ្លៃជួលអប្បបរមាសរុបនាពេលអនាគត ក្រោមកិច្ចសន្យាភតិសន្យាដែលមិនអាចលុបចោលបាន មានដូចខាងក្រោម ៖

| | 2016 | | 2015 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| មិនលើសពី1ឆ្នាំ | 3,754,417 | 930,002 | 2,704,499 | 667,778 |
| ពី1ឆ្នាំ ទៅ5ឆ្នាំ | 10,990,283 | 2,722,389 | 8,322,107 | 2,054,841 |
| លើសពី5ឆ្នាំឡើងទៅ | 1,864,031 | 461,737 | 46,401 | 11,457 |
| | 16,608,731 | 4,114,128 | 11,073,007 | 2,734,076 |

### (ខ) កិច្ចសន្យាផ្សេងៗ

គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2016 ក្រុមហ៊ុនមានកិច្ចសន្យាដែលនៅមិនទាន់ទូទាត់ចំនួន 109ពាន់ដុល្លារអាមេរិក ដែលត្រូវបង់សម្រាប់គម្រោងប្រព័ន្ធកុំព្យូទ័រធនាគារថ្មី។

## 26. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

សកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុនប្រឈមនឹងហានិភ័យហិរញ្ញវត្ថុផ្សេងៗមួយចំនួន ដូចជា ហានិភ័យឥណទាន ហានិភ័យទីផ្សារ (រួមមានហានិភ័យរូបិយប័ណ្ណ ហានិភ័យអត្រាការប្រាក់ ហានិភ័យតម្លៃ) និងហានិភ័យសាច់ប្រាក់ងាយស្រួល។ អាជីវកម្មហិរញ្ញវត្ថុភាគច្រើនប្រឈមមុខនឹងហានិភ័យ ក្នុងនោះហានិភ័យប្រតិបត្តិការគឺជាផលវិបាកដែលពិបាកជៀសរួចណាស់ក្នុងដំណើរការអាជីវកម្ម។ ក្រុមហ៊ុនមិនប្រើឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ (derivative financial instrument) ដូចជាកិច្ចសន្យាប្តូររូបិយប័ណ្ណ (foreign exchange contract) និងការផ្លោះប្តូរអត្រាការប្រាក់ (interest rate swaps) ដើម្បីគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ខ្លួននោះទេ។

ទ្រព្យសកម្មហិរញ្ញវត្ថុគឺជាសិទ្ធិដែលមានចែងក្នុងកិច្ចសន្យាដើម្បីទទួលបានសាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀតពីអង្គភាពមួយផ្សេងទៀត។ ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ថ្នាក់ជាឥណទាន និងគណនីត្រូវទទួលផ្សេងៗ ដែលរួមមានសាច់ប្រាក់ក្នុងដៃ សមតុល្យនៅធនាគារកណ្តាល ប្រាក់បញ្ញើនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ ឥណទានអតិថិជន និងទ្រព្យសកម្មផ្សេងទៀត។

បំណុលហិរញ្ញវត្ថុគឺជាកាតព្វកិច្ចដែលមានចែងក្នុងកិច្ចសន្យាក្នុងការប្រគល់សាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀតទៅឱ្យអង្គភាពមួយផ្សេងទៀត។ បំណុលហិរញ្ញវត្ថុត្រូវបានចាត់ថ្នាក់ថាជាបំណុលផ្សេងៗ ដែលរួមមានប្រាក់បញ្ញើរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ ប្រាក់បញ្ញើអតិថិជន ប្រាក់កម្ចី និងបំណុលផ្សេងៗទៀត។

## 26. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 26.1 ហានិភ័យឥណទាន

ក្រុមហ៊ុនប្រឈមនឹងហានិភ័យឥណទាន ជាហានិភ័យដែលសមភាគីធ្វើឱ្យមានការខាតបង់ផ្នែកហិរញ្ញវត្ថុដល់ក្រុមហ៊ុន ដោយសារការខកខានមិនបានបំពេញកាតព្វកិច្ចសងបំណុល។ ហានិភ័យឥណទានគឺជាហានិភ័យដែលមានសារសំខាន់ជាងគេបំផុតក្នុងអាជីវកម្មរបស់ក្រុមហ៊ុន។ ភាគច្រើនហានិភ័យឥណទានកើតឡើងពីការផ្តល់ឥណទានជូនអតិថិជន។ ការគ្រប់គ្រងហានិភ័យឥណទានត្រូវបានធ្វើឡើងដោយគណៈកម្មាធិការឥណទានរបស់ក្រុមហ៊ុន។

សកម្មភាពនៃការផ្តល់ឥណទាន ត្រូវបានធ្វើឡើងដោយស្របទៅតាមគោលការណ៍ឥណទានរបស់ក្រុមហ៊ុន ដើម្បីធានាការសម្រេចបាននូវគោលបំណងជាទូទៅនៅក្នុងតំបន់ដែលត្រូវឱ្យខ្ចី មានន័យថាត្រូវសម្រេចបាននូវសំពៀតឥណទានល្អនិងរឹងមាំ ហើយអាចកាត់បន្ថយហានិភ័យឥណទានបាន។ គោលការណ៍ឥណទានរួមមានគោលការណ៍ក្នុងការផ្តល់ឥណទាន គោលការណ៍ស្តីពីវត្ថុបញ្ចាំ ព្រមទាំងដំណើរការ និងនីតិវិធីអនុម័តឥណទាន ដើម្បីធានានូវអនុលោមភាពតាមគោលការណ៍ណែនាំរបស់ធនាគារកណ្តាល។

### (ក) ការវាស់វែងហានិភ័យឥណទាន

ក្រុមហ៊ុនវាយតម្លៃលទ្ធភាពនៃការខកខានមិនបានសងបំណុលរបស់អ្នកខ្ចីប្រាក់ជាឯកត្តជន ដោយផ្តោតលើការព្យាករណ៍ប្រាក់ចំណេញ និងលំហូរសាច់ប្រាក់របស់អ្នកខ្ចីប្រាក់។ គណៈកម្មាធិការឥណទានទទួលខុសត្រូវក្នុងការអនុម័តផ្តល់ឥណទានជូនអតិថិជន។

### (ខ) ការគ្រប់គ្រងកម្រិតហានិភ័យ និងគោលការណ៍បន្ថយហានិភ័យ

ក្រុមហ៊ុនធ្វើប្រតិបត្តិការនិងផ្តល់ឥណទានជូនឯកត្តជន ឬសហគ្រាសធុនតូចនិងមធ្យម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនគ្រប់គ្រងកម្រិត និងត្រួតពិនិត្យការប្រមូលផ្តុំហានិភ័យឥណទាន នៅពេលដែលវាត្រូវបានរកឃើញ។

ក្រុមហ៊ុនប្រើប្រាស់គោលការណ៍និងការអនុវត្តជាច្រើន ដើម្បីបន្ថយហានិភ័យឥណទាន។ គោលការណ៍ជាប្រពៃណីបំផុតក្នុងចំណោមគោលការណ៍ទាំងអស់នេះ គឺការធានាដោយដាក់វត្ថុបញ្ចាំចំពោះឥណទានអតិថិជន ដែលជាការអនុវត្តទូទៅមួយ។ ក្រុមហ៊ុនអនុវត្តគោលការណ៍ណែនាំស្តីពីការទទួលយកបាននូវចំណាត់ថ្នាក់ជាក់លាក់នៃវត្ថុបញ្ចាំ ឬការបន្ថយហានិភ័យឥណទាន។

26. **ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ** (ត)

26.1 **ហានិភ័យឥណទាន** (ត)

(គ) **ការថយចុះតម្លៃនិងគោលការណ៍សំវិធានធន**

ក្រុមហ៊ុនត្រូវបានតម្រូវឱ្យអនុវត្តការធ្វើចំណាត់ថ្នាក់ឥណទាននិងសំវិធានធន ស្របតាមប្រកាសលេខ ធ7-02-186 ប្រ.ក. ចុះថ្ងៃទី13 ខែកញ្ញា ឆ្នាំ2002 ស្តីពីការធ្វើចំណាត់ថ្នាក់ឥណទាននិងសំវិធានធន។ ធនាគារកណ្តាលតម្រូវឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធ្វើចំណាត់ថ្នាក់ឥណទានរបស់ខ្លួនជាបួនថ្នាក់ ហើយត្រូវប្រាកដថាគ្រឹះស្ថានរបស់ខ្លួនបានបំពេញកាតព្វកិច្ចសំវិធានធនជាក់លាក់អប្បបរមា អាស្រ័យទៅតាមចំណាត់ថ្នាក់ដែលពាក់ព័ន្ធ ដោយមិនគិតពីទ្រព្យសកម្មផ្សេងៗដែលបានដាក់ជាវត្ថុបញ្ចាំ (លើកលែងតែសាច់ប្រាក់) (សូមមើលកំណត់សម្គាល់ 2.7)។

លើសពីនេះ សំវិធានធនទូទៅត្រូវបានកត់ត្រាបន្ថែមទៅលើសំវិធានធនជាក់លាក់ដែលមានស្រាប់ ចំពោះឥណទានមិនដំណើរការ ដើម្បីធ្វើឱ្យប្រាកដថាអនុបាត គ្របដណ្តប់ហានិភ័យមានរហូតដល់ 100%។

(ឃ) **ហានិភ័យឥណទានអតិបរមាមុនការកាន់កាប់វត្ថុបញ្ចាំ ឬមុនការពង្រឹងឥណទាន**

| | 2016 | | 2015 | |
|---|---|---|---|---|
| | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** |
| *ហានិភ័យឥណទានទាក់ទិននឹង* | | | | |
| *ទ្រព្យសកម្មក្នុងតារាងតុល្យការ៖* | | | | |
| ឥណទានអតិថិជន (កំណត់សម្គាល់ 7) | 874,171,085 | 216,539,778 | 760,988,930 | 187,898,501 |
| សមតុល្យនៅធនាគារ (កំណត់សម្គាល់ 6) | 89,398,093 | 22,144,685 | 70,717,376 | 17,461,080 |
| ទ្រព្យសកម្មផ្សេងៗ | 13,272,358 | 3,287,678 | 12,856,573 | 3,174,462 |
| | 976,841,536 | 241,972,141 | 844,562,879 | 208,534,043 |

តារាងខាងលើនេះ បង្ហាញពីស្ថានភាពអាក្រក់បំផុតនៃហានិភ័យរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2016 និងថ្ងៃទី31 ខែធ្នូ ឆ្នាំ2016 ដោយមិនគិតដល់វត្ថុបញ្ចាំឬការពង្រឹងឥណទានផ្សេងទៀតទេ។ ចំពោះទ្រព្យសកម្មក្នុងតារាងតុល្យការ ហានិភ័យដែលបានបង្ហាញខាងលើ គឺផ្អែកទៅលើតម្លៃយោងដុល ដកការខាតបណ្តាលមកពីការថយចុះតម្លៃផ្សេងៗ។

ដូចបានបង្ហាញខាងលើ 89.49% នៃហានិភ័យអតិបរមាសរុប គឺកើតមកពីឥណទានអតិថិជន (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2015 ៖ 90.10%)។

គណៈគ្រប់គ្រងមានជំនឿថា ខ្លួនមានលទ្ធភាពបន្តការគ្រប់គ្រង និងទ្រទ្រង់ហានិភ័យឥណទានរបស់ក្រុមហ៊ុនដែលបណ្តាលមកពីឥណទានអតិថិជន ឱ្យស្ថិតក្នុងកម្រិតអប្បបរមា តាមវិធីដូចខាងក្រោម៖

- 98.21% នៃឥណទានអតិថិជន ត្រូវបានចាត់ថ្នាក់ជាឥណទានមិនហួសកាលកំណត់សង និងមិនថយចុះតម្លៃ (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2015 ៖ 99.7%) និង
- ក្រុមហ៊ុនបានអនុវត្តនីតិវិធីការជ្រើសរើសយ៉ាងម៉ត់ចត់ ក្នុងការផ្តល់ឥណទានជូនអតិថិជន។

## 26. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

## 26.1 ហានិភ័យឥណទាន (ត)

### (ខ) ឥណទានអតិថិជន

ឥណទានអតិថិជនត្រូវបានសង្ខេបដូចខាងក្រោម ៖

| | 2016 | | 2015 | |
|---|---|---|---|---|
| | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** |
| ឥណទានអតិថិជនមិនហួសកាល កំណត់សងនិងមិនថយចុះតម្លៃ | 870,436,760 | 215,614,754 | 760,565,245 | 187,793,887 |
| ឥណទានអតិថិជនហួសកាលកំណត់សង ប៉ុន្តែមិនថយចុះតម្លៃ | 3,734,325 | 925,024 | 423,685 | 104,614 |
| ឥណទានអតិថិជនថយចុះតម្លៃ | 12,107,033 | 2,999,018 | 1,848,153 | 456,334 |
| ឥណទានអតិថិជនដុល | 886,278,118 | 219,538,796 | 762,837,083 | 188,354,835 |
| សំវិធានធនឥណទានអាក្រក់ និងសង្ស័យ | (12,107,033) | (2,999,018) | (1,848,153) | (456,334) |
| ឥណទានអតិថិជនសុទ្ធ | 874,171,085 | 216,539,778 | 760,988,930 | 187,898,501 |

